# ការសម្ភាសរបស់អ្នកមីង នាង សុនារី

កះ អ្នកសម្ភាស ញ៉ែម សុគន្ធា ខះ អ្នកត្រូវគេសម្ភាស នាង សុនារី

គះ ប្អូនស្រី(ប្អូនស្រីអ្នកមីង នាង សុនារី)

## <u>ជីវប្រវត្តិសង្ខេបរបស់អ្នកមីង នាង សុនារី</u>

អ្នកមីងនាង សុនារីគឺគាត់កើតមកក្នុងត្រកូលមួយដែលមានជីវភាពសមរម្យ ហើយគាត់បានប្រាប់ថាយាយរបស់គាត់គឺបានជាប់លោហិតជារាជវង្សានុវង្សផងដែរ។ហើយគាត់មានជីតាដែលចេះប្រើមន្តអាគមន៍ទៀតផង។គាត់បានឆ្លងកាត់នៅក្នុងរបបលន់ នល់ ហើយគាត់ថានៅទីក្រុងពុំសូវមានការទម្លាក់គ្រាប់ច្រើនប៉ុន្មានទេ ហើយគាត់នៅពេលនោះគឺស្ថិតនៅក្នុងភាពជាយុវវ័យហើយគាត់បានច្រៀងរាំជាមួយមិត្តភក្តិរបស់គាត់បានសប្បាយផងដែរ តែជួនកាលក៏មានភាពភ័យខ្លាចផងដែរ។ហើយបន្ទាប់មកគាត់បានចូលមកក្នុងរបបប៉ុល ពតគឺគាត់បានចេញពីផ្ទះពេលដែលពួកប៉ុល ពតដេញគឺគាត់ស្លៀកតែសារុងដ៏ចាស់មួយទៅព្រោះគាត់គិតថានឹងបានត្រលប់មកផ្ទះវិញ ប៉ុន្តែគឺគ្មានទេគាត់ត្រូវបានគេបណ្តាញទៅដើររហូតហើយគាត់បានជិះកប៉ាល់ ទៅខេត្តកំពង់ធំហើយតាមផ្លូវទឹកមានព្យុះហើយមនុស្សច្រើននៅលើកប៉ាល់គឺលំបាកណាស់ ហើយមានមនុស្សបានស្លាប់ដោយសារតែភាពដ៏សែនលំបាកនៅលើទីនោះ។គាត់បានទទួលការហូបចុកដ៏សែនពិបាក។អ្នកមីងគាត់បានទទួលការសិក្សាបានច្រើនគួរសមដែរ។គាត់ត្រូវបានប៉ុល ពតឱ្យរៀបការជាមួយមនុស្សដែលគាត់មិនស្គាល់ហើយគាត់ក៏រៀបការ ហើយមានកូនចំនួន៣នាក់ហើយរស់នៅរហូតដល់សព្វថ្ងៃ។

កះ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីង នាង សុនារីដែលបានឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ្នកមីងហើយនាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា ជាអ្នកសម្ភាសអ្នកមីងនៅក្នុងថ្ងៃនេះហើយការសម្ភាសរបស់យើងគឺប្រព្រឹត្តទៅនៅក្នុងថ្ងៃទី៣០ ខែ តុលា ឆ្នាំ២០១៧ ហើយការ សម្ភាសនេះគឺនៅរាជធានីភ្នំពេញប៉ុន្តែសង្កាត់អីអ្នកមីងអាចសូមរៀបរាប់។អ្នកមីងនៅសង្កាត់អីគេដែរ?

ខ៖ ខ្ញុំ ជាដំបូងខ្ញុំសូមអរគុណដល់ក្មួយស្រីដែលបានចូលមកសម្ភាសខ្ញុំឱ្យដឹងអំពីជីវប្រវត្តិផ្សេងៗរបស់ខ្ញុំនៅក្នុងសម័យអតីតកាលហើយនឹងបច្ចុប្បន្ន ចាសហើយនាងខ្ញុំឈ្មោះ នាងសុនារី រស់នៅភូមិព្រៃកតាឡុង សង្កាត់ចាក់អង្រែក្រោម រាជធានីភ្នំពេញចាស។

ក៖ ចាសហើយអញ្ចឹងអ្នកមីង តើអ្នកមីងឈ្មោះពេញមិញឈ្មោះអីគេដែរមីង?

ខ៖ នាង សុនារី។

ក៖ ចាសអញ្ចឹងអ្នកមីងមានឈ្មោះ ហៅក្រៅអត់?

ខ៖ ហៅក្រៅហៅ អាស្រី ឬមួយ អារី ចាស២ហ្នឹង។

ក៖ តែ២ហ្នឹងទេមីងហ្ន៎?

ខ៖ ចាសស្រីធំ ស្រីទូចបងប្អូនខ្ញុំចាស។

ក៖ ចាសមានអ្នកណាគេដាក់អ្នកមីងរហ័ស្សនាមអីអត់?

ខ៖ អត់មានទេ។

ក៖
ដោយសារភាគច្រើនក្មេងខ្មែរយើងនៅក្មេងៗអញ្ចឹងច្រើនតែដាក់រហ័ស្សនាមអញ្ចឹងទៅណា។

ខ៖ ចាសហ្វយ...ចេះតែមានហើយ។

ក៖ ដាក់លេងអញ្ចឹងហា។

ខ៖ ឈ្មោះកាទ្រូត ឈ្មោះ កាទ្រីត ឈ្មោះអីគេហៅ ចាស់ៗពីដើម យើងកាចយើងឆ្នាស់ហ្ន៎...

ចាស។

ក៖ ចាសអញ្ចឹងតើអ្នកមីងតើសព្វថ្ងៃអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុ ៦០ ឆ្នាំហើយ។

ក៖ ចាសតើអ្នកមីងកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ ខ្ញុំកើតនៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៥៧។

ក៖ ចាសចុះអ្នកមីងសម្រាប់ឆ្នាំខ្មែររបស់យើងអ្នកមីងកើត ជាឆ្នាំសត្វអីគេដែរ?

ខ៖ សត្វមាន់។

ក៖ ចាសឆ្នាំរកា។

ខ៖ ឆ្នាំរកាហ្នឹងឯង។

ក៖ ហ្នឹងហើយ។អញ្ចឹងអ្នកមីងភូមិកំណើត
ទីកន្លែងកំណើតរបស់អ្នកមីងហា...អ្នកមីងកើតនៅភូមិ ឃុំ ស្រុក ខេត្តអីគេដែរ?

ខ៖ ខ្ញុំកើតនៅភូមិព្រែកតាឡុងហ្នឹង សង្កាត់ចាក់អង្រែក្រោម ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល អាហ្នឹងស្រុកកំណើត។

ក៖ ចាសចុះពេលមុនគេហៅនៅហ្នឹងកណ្ដាលស្ទឹងទេចុះ?

ខ៖ ចាសកណ្ដាលស្ទឹង។

ក៖ ចាសអញ្ចឹងអ្នកមីងតើអ្នកមីងមានបងប្អូនប្រុសស្រីចំនួនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូនប្រុសស្រីបង្កើត៦នាក់។ស្រី៣ ប្រុស៣។

ក៖ ចាសហើយអ្នកមីងជាកូនទីប៉ុន្មានវិញ?

ខ៖ ខ្ញុំជាកូនទី២នៅក្នុងគ្រួសារចាស បងប្រុសខ្ញុំស្លាប់ហើយ។

ក៖
ចាសអញ្ចឹងអ្នកមីងតើអ្នកមីងចាំឈ្មោះបងប្អូនរបស់អ្នកមីងទាំងអស់អត់តើបងគេរហូតដល់ពៅគេគាត់ឈ្មោះអីគេខ្លះ?

ខ៖ ចាំ។បងខ្ញុំទីមួយស្លាប់នៅក្នុងជំនាន់ប៉ុល ពត គេយកទៅសម្លាប់គឺគាត់ឈ្មោះ សុខ សុនារ៉ា ចាសហើយកាលហ្នឹងគាត់ស្លាប់អាយុជាង២០ហើយបងប្រុសទី១
ហើយបន្ទាប់មកខ្ញុំហើយបន្ទាប់ មកប្អូនប្រុសខ្ញុំទី៣ឈ្មោះ សុខ សុវណ្ណា
ចាសអត់សួរអាយុអីទេណោះ?

ក៖ អត់ តែគ្រាន់តែប្រាប់ឈ្មោះគាត់អញ្ចឹងហា។

ខ៖ ហើយប្អូនស្រីទី៣ទៀត គឺនាង សុធីតា ។

ក៖ ចាស!

ខ៖ អាប្អូនប្រុសទី៤ សុខ សុមីនា ប្អូនស្រី ពៅគឺនាង សុមករា នេះ។

ក៖
ចាសហ្នឹងហើយ។បងប្អូនអ្នកមីងសុទ្ធតែស្អាតៗ។ចាសអញ្ជឹងអ្នកមីងតើអ្នកមីងចងចាំសាច់រឿងអី
គេខ្លះជាមួយនឹងពួកគាត់ហា...ថាដូចជាពីតូចក៏ដូចជាការរស់នៅជាមួយពួកគាត់មកដល់ឥឡូវ
ហ្នឹងវាម៉េចដែរ?

ខ៖
ក្នុងការរស់នៅរបស់ខ្ញុំនៅហ្នឹងតាំងពីក្មេងៗជាមួយគ្នាគឺថាបងប្អូនខ្ញុំរស់នៅមានសេចក្ដីសុខចា
ស ការរស់នៅគ្រាន់តែជីវភាពគ្រួសារឪពុកខ្ញុំគាត់ថា
គាត់ថាមន្រ្តីរាជការដែរប្រាក់ខែវាតិចនិយាយទៅគាត់មាន បើនិយាយទៅគាត់មានគ្រួសារគាត់
គាត់មានប្រពន្ធទាល់តែ៣ហ្នុ..។

ក៖ ច្រើនម្ល៉េះ?

ខ៖ ៣ ៤ហ្នុ...ប៉ុន្តែគ្រាន់តែខ្ញុំដឹង ខ្ញុំដឹងតែ៣ទេ ទី១ខ្ញុំអត់ដឹងទេថាគាត់លែងគ្នាហើយទី ២
គាត់ងងឹតភ្នែក គាត់បានកូនប្រុសមួយ
ងងឹតភ្នែកទៅប៉ាខ្ញុំក៏គាត់ទុកឱ្យនៅរៀនធម៌រៀនអីនៅវត្តទៅស្រុកគាត់
ហើយបើទី៣អាហ្នឹងគាត់ខ្ញុំហៅគាត់ម៉ាក់អ៊ុំៗហ្នឹងគាត់រូបគាត់នេះហ្នឹងហើយ។

ក៖ ចាស!

ខ៖
ហ្នឹងហើយគាត់ហ្នឹងនៅជាមួយខ្ញុំសព្វថ្ងៃគាត់នៅជាមួយខ្ញុំហើយនឹងម៉ាក់ខ្ញុំក្រោយហ្នឹងនៅ២
នាក់នៅជាមួយគ្នារហូត ចាសហើយខ្ញុំរស់នៅដូចថា២នាក់ម្ដាយខ្ញុំ
ទាំង២ហ្នឹងគាត់តាំងពីអត់ពីប៉ាខ្ញុំទៅ
គាត់រស់នៅដូចថាអត់ចេះឈ្លោះគ្នាទេណាស់ជាមួយកូនទាំងអស់គ្នាហ្នឹងចាស។

ក៖ ម្ដាយមួយប្រពន្ធរបស់ប្ដីហាំ...ឪពុករបស់អ្នកមីងពេលមុនហោំ?

ខ៖ ឪពុកចាំមើលម្ដាយនេះហាំ...(គាត់ចង្អុលនៅក្នុងរូបភាព)។

ក៖ ចាស!

ខ៖ គាត់ម្ដាយទី៣យើងថា ទី៣ចុះ។

ក៖ ម្ដាយបង្កើតមីងហោ?

ខ៖ មិនមែនទេ ម្ដាយបង្កើតក្រោយទេ ខ្ញុំចុង។

ក៖ ចាសហ្ន៎...!

ខ៖ ខ្ញុំចុងគេ។

ក៖ ចាស!

ខ៖ ហើយគាត់មានកូនប្រុស៤នាក់ដែរប៉ុន្តែគាត់នៅក្នុងជំនាន់ប៉ុល ពតស្លាប់អស់រលីងហើយខ្ញុំអត់លើកពីឈ្មោះគាត់ទេ ខ្ញុំលើកតែសាច់បង្កើតរបស់ខ្ញុំទេណាស់។

ក៖ ចាស!

ខ៖ តែម្ដាយមួយឪពុក មួយទេ ហើយគាត់ស្លាប់អស់ហើយ ហើយគាត់មករស់នៅជាមួយខ្ញុំហើយនឹងម្ដាយខ្ញុំហើយនឹងកូនចុងក្រោយបង្អស់ហ្នឹង ហើយរហូតដល់ពេលគាត់ចាស់ស្លាប់ទៅហើយម្ដាយខ្ញុំគាត់ក៏អញ្ចឹងដែរគាត់ក៏ចាស់ស្លាប់ប្រហែលជា៣ ៤ឆ្នាំហ្នឹងដែរ។

ក៖ ចាសហើយអត់ដែលមានទំនាស់នឹងគ្នាអីទេ?

ខ៖ អត់ដែលមានទំនាស់នឹងគ្នាអីទេ មិនដែលឈ្លោះគ្នាទេ អឺ...ធម្មតាចាននៅក្នុងរាវវាចេះតែប៉ះពាល់គ្នាបន្តិចបន្តួចហើយវាមិនមែនថាដល់ឯណាវ៉ៃវាយគ្នាអីអត់ទេ គ្រាន់តែថាទើសពាក្យសម្ដីបន្តិចបន្តួចកូនចៅអីហ្នឹងហា។

ក៖ ហ្ន៎...!

ខ៖ តែគាត់ស្រួលណាស់ គាត់ស្រលាញ់ពួកខ្ញុំដូចកូនបង្កើតអញ្ចឹងម្ដាយធំខ្ញុំហ្នឹង។

ក៖ ចាសហើយរស់នៅជាមួយគ្នាសុខស្រួលអញ្ចឹងមកមីងណោះ?

ខ៖ ចាសសុខស្រួលណាស់ចាស។

ក៖ ចាសចុះអ្នកមីងមានចាំអីជាមួយបងប្អូនអីបន្ថែមទៀតទេ?

ខ៖ សម្រាប់បងប្រុសខ្ញុំដំបូងខ្ញុំនៅតូចគាត់ចូលធ្វើការនៅខាងទាហានជើងទឹក។

ក៖ ចាស!

ខ៖ ពេលរៀនចប់ហា...រៀនចប់យើងហ្នឹង យើងជំនាន់លន់ នល់ ចាសហើយមកហើយគេកូនសិស្សតែត្រឹមរៀនចប់បាក់ឌុបអីចេញធ្វើការអស់ហើយចាសគ្រាន់គាត់ចូលធ្វើទាហានជើង ទឹកហ្នឹងនៅវត្តភ្នំ។

ក៖ ចាស!

ខ៖ ហើយគាត់នៅថានៅគ្រប់គ្រងលើគ្រួសារហា...ប៉ាខ្ញុំគាត់អាត្រែតហើយគាត់អត់មានប្រាក់ខែអីចិញ្ចឹមកូន កូនច្រើនជិត១០កូន។

ក៖ ចាសទាំងមុនទាំងក្រោយ។

ខ៖ ចាសទាំងមុនទាំងក្រោយ ហើយគាត់គ្រប់គ្រងកូនម៉េចបានបើប្រាក់ខែ២០០០ អាត្រែតហ្នឹងជំនាន់លន់ នល់ហើយបានបងខ្ញុំហ្នឹងគាត់រកបាន គាត់ខាងគណនេយ្យ ដូចថាដើរបើកលុយតាមទាហានហា...ជិះកប៉ាល់ហោះទៅណោះទៅណោះកន្លែងណាទាហាននៅអញ្ចឹងយើងចុះបើកលុយឱ្យគេហើយគាត់រកលុយបានណាស់កាន់លុយទាំងការ៉ុង។

ក៖ អ្នកកាន់លុយ?

ខ៖ អ្នកកាន់លុយ ប៉ុន្តែលុយជំនាន់ហ្នឹងចាយដូចក្រដាសអញ្ចឹងវាថោក លុយថោកណាស់។

ក៖ ចាស!

ខ៖ ថោកពេក សាច់ជ្រូក ១កាំអីប៉ុន្មានពាន់ហ្ន៎...ហែងទាន់ហែងដែលឃើញអាលុយរូបគោទេ?

ក៖ ដូចធ្លាប់។

ខ៖ ហ្នឹងហើយលុយរូបគោពីដើមធំណាស់ប៉ុនៗណែក។

ក៖ ចាស!

ខ៖ ចេញទៅទាំងការ៉ុងក្រវែងចោល។

ក៖ ហ្នឹងហើយ។

ខ៖ ចាសវាអញ្ចឹងហើយគាត់រ៉ាប់រងចិញ្ចឹមក្រុមគ្រួសារទាំងអស់គាត់អត់ទាន់យកប្រពន្ធទេ។

កៈ ចាស!

ខៈ រួចដល់ពេលហ្នឹងទៅអាពត គាត់ថាគេក្តាប់ប្រវត្តិរូបរបស់យើងថាយើងជាអតីតទាហាន

អញ្ចឹងហា...ហើយគេយកទៅវ៉ៃចោលទៅ។

កៈ ឪពុករបស់អ្នកមីង?

ខៈ បងប្រុសខ្ញុំ បើឪពុកខ្ញុំអត់ទេគាត់ជាមន្ត្រីរាជការ គាត់អាត្រែតហើយប៉ុន្តែគាត់ស្លាប់ដោយសារជម្ងឺទេ។

កៈ គាត់ស្លាប់មុនប៉ុល ពតអញ្ចឹងហោ៎?

ខៈ នៅក្នុងប៉ុល ពត។

កៈ ហ្ហ៎...!

ខៈ ពេលដែលជម្លៀសទៅយើងទៅទាំងក្រុមគ្រួសារហើយគាត់
ចាស់ហើយអាយុ៦០ជាងហើយហ្នឹង ដើរទៅបាចត្រីបាចអី
គាត់អ្នកកាន់សីលផងហើយដល់ពេលអត់ពេកសុខចិត្តបាចត្រីហើយប្រាប់ប្អូនពៅខ្ញុំនេះថាកុំ
មាត់ថាអញបាចត្រីហើយយកទៅស៊ី។

កៈ អូយ...អញ្ចឹងពិបាកណាស់អ្នកមីងណោះ?

ខៈ ចាស!

កៈ
ហើយចុះសម្រាប់បងប្អូនដទៃផ្សេងទៀតភាគច្រើនលេងអីគេមួយគ្នាដែរនៅពេលពីក្មេងហា៎?

ខៈ លេងហ្គេម។

កៈ លេងហ្គេម?

ខៈ ខ្ញុំអត់ដឹងថាហ្គេមអីជំនាន់ហ្នឹង លេងលោតអន្ទាក់ គប់វង់អី
ចុះជំនាន់ហ្នឹងក្មេងលេងដោយក្មេងប្រុសទៅ
អាចរិកក្មេងស្រីលេងប៉ៃឡុកប៉ៃឡរអីអញ្ចឹងទៅជាមួយគ្នាទៅ
អឺ...ប៉ុន្តែថាក្មេងវាមិនសូវបានសុខជាមួយគ្នា លេងចេះតែវ៉ៃគ្នាខ្លះហើយ។

កៈ ហើយមានដែលម៉ែរ៉ែអត់ដល់ពេលឈ្លោះគ្នា?

ខៈ ហូ...រ៉ែ រ៉ែរត់ត្រង់កន្ទុយដូចអីអញ្ចឹង។

កៈ តែសប្បាយម៉្យាងដែរមីងពេលនៅក្មេង?

ខៈ ចាស!

កៈ
ចាសអញ្ចឹងអ្នកមីងតើពេលនេះអឺ...ដូចជាបងប្អូនអ្នកមីងគាត់រស់នៅឯណាខ្លះដែរហើយពួកគាត់កំពុងតែធ្វើការឬក៏រកស៊ីអីគេដែរ?

ខៈ សម្រាប់បងប្អូនខ្ញុំសព្វថ្ងៃនៅជុំគ្នាទេ យើងនៅជិតគ្នាទាំងអស់ផ្ទះបែក
បែកផ្ទះផ្សេងគ្នាតែផ្ទះនៅជិតគ្នា។

កៈ ចាស!

ខៈ ខ្ញុំបងខ្ញុំនៅផ្ទះមួយប្ដីខ្ញុំក្រុមគ្រួសារកូនចៅខ្ញុំទៅ
ហើយប្អូនស្រីខ្ញុំ២នាក់នេះគេនៅនេះជាមួយប្អូនរបស់ខ្ញុំ៣នាក់។

កៈ ចាស!

ខៈ ហើយមួយចំហៀងខាងណោះប្អូនប្រុសរបស់ខ្ញុំដែរ
គេនៅជាមួយប្រពន្ធគេហើយនឹងកូនគេ ។

កៈ ចាសអញ្ចឹងនៅជុំគ្នាទំាងអស់?

ខៈ ជុំគ្នាទាំងអស់ចាស។

កៈ ហើយតើជីវភាពរបស់ពួកគាត់ទាំងអស់ហ្នឹងយ៉ាងម៉េចដែរអ្នកមីង?ដូចអត់អីឯណាអី?

ខៈ ជីវភាពរបស់គាត់គឺថាវាសមរម្យវាអាចរស់បានវាមិនពិបាកពេកទេ ចាសដោយសារគាត់

មានការងារធ្វើមុនរបររកស៊ីអញ្ចឹងទៅវាអភ័ព្វតែខ្ញុំដែលអត់ចេះរកអីនឹងគេ។

កៈ ចាសអញ្ចឹងសម្រាប់អ្នកមីងតើមុខរបរសព្វថ្ងៃអ្នកមីងធ្វើអីគេទៅអញ្ចឹង?

ខ៖ ខ្ញុំហ៎...មេផ្ទះ នៅផ្ទះមើលចៅ
មើលផ្ទះសម្បែងយើងនៅមើលផ្ទះសម្បែងដាំបាយដាំទឹកឱ្យចៅឱ្យកូនញ៉ាំទៅគេទៅធ្វើការរក លុយមកចិញ្ចឹមយើង។

ក៖ ចាសដល់ពេលអ្នកមីងមានអាយុច្រើនហើយអញ្ចឹងត្រូវតែធ្វើមួយហ្នឹងអញ្ចឹងហ្ន៎...?

ខ៖ ចាស!

ក៖ អញ្ចឹងអ្នក មីងមិញភ្លេចសួរមីងថាតើទីលំនៅរបស់អ្នកមីងបច្ចុប្បន្នគេហៅអីគេដែរ?

ខ៖ ទីលំនៅនេះហ៎?

ក៖ ចាស!

ខ៖ គេហៅភូមិព្រៃកតាឡុង៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌ មានជ័យ  រាជធានីភ្នំពេញ។

ក៖ ដូរមិនមែនស្រុកកណ្តាលស្ទឹងដូចមុនទេ?

ខ៖ ចាសអត់មានកណ្តាលស្ទឹងទេ។

ក៖ ចាសគេដូរយូរហើយមីងណេះ?

ខ៖ ដូរយូរហើយតាំងខ្ញុំនៅទើបតែមកដល់ហ្ន៎...បែកអាពតចូលមកបានប៉ុន្មានប្តូរ។

ក៖ ចាសអញ្ចឹងអ្នកមីងតើម្តាយអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ម្តាយខ្ញុំឈ្មោះ អ៊ុំ ស៊ីវន។

ក៖ ចាសចុះចំណែកឪពុករបស់អ្នកមីងវិញ?

ខ៖ ឈ្មោះ សុខ នាង។

ក៖ ឈ្មោះសុខ នាង?ចុះអ្នកមីងសម្រាប់ម្តាយរបស់អ្នកមីងគាត់នៅរស់ឬក៏គាត់ស្លាប់ហើយ?

អ្នកមីងម្តាយរបស់អ្នកមីងហា៎?

ខ៖ ម្តាយខ្ញុំគាត់ស្លាប់ហើយចាស។

កៈ
ចាសអញ្ចឹងអ្នកមីងសម្រាប់ម្ដាយរបស់អ្នកមីងគាត់មានថ្ងៃខែឆ្នាំកំណើតរបស់គាត់ថ្ងៃទីប៉ុន្មានដែរ?

ខៈ ខ្ញុំអត់ដឹងដែរ មើលខ្ញុំឈប់មើល។

កៈ អ្នកមីងអាចមើលនៅក្នុងសំបុត្រកំណើតបានហាំ...។

ខៈ ហ្ន៎...អានេះអ៊ុំ ស៊ីវន ថ្ងៃទី០៧ ខែកញ្ញា ចាសថ្ងៃកំណើតគាត់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៣០។

កៈ ចាសអញ្ចឹងទីកន្លែងកំណើតរបស់គាត់នៅឯណាមីងអាន?

ខៈ គាត់នៅឃុំចាក់អង្រែ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

កៈ ចាសអ្នកមីងចាំឆ្នាំខ្មែរម្ដាយរបស់អ្នកមីងអត់?

ខៈ ឆ្នាំខ្មែរគាត់ឆ្នាំច ឆ្នាំឆ្កែ។

កៈ ចាសអញ្ចឹងអ្នកមីងតើអ្នកមីងមានអនុស្សាវរីយ៍អីគេខ្លះជាមួយម្ដាយរបស់អ្នកមីង?

ខៈ សម្រាប់គាត់ខ្ញុំមានអនុស្សាវរីយ៍ច្រើនណាស់។

កៈ ម៉េចអ្នកមីងអាចរៀបរាប់អញ្ចឹងហាំ?

ខៈ ចាសគាត់ធ្លាប់ដូចថាមើលថៃយើងពេលដែលយើងនៅតូច ថៃទាំយើងព្រោះអីខ្ញុំដំបូងស្រីតែមួយទេនិយាយពីស្រលាញ់ ជំទើរជំទើតអង់អាច ឆ្នាស់ឆ្នើមណាស់ ហើយអ្នកណាធ្វើអីបន្តិចគឺអត់បានទេប៉ះពាល់អត់បានទេ
អាហ្នឹងប៉ាខ្ញុំម៉ាក់ខ្ញុំគាត់ស្រលាញ់ខ្ញុំព្រោះខ្ញុំស្រីតែមួយដំបូងអត់ទាន់មានប្អូនខ្ញុំទៀតទេ។

កៈ ចាស!

ខៈ ហើយគាត់ស្រលាញ់យើងចេះមើល
ថៃយើងសព្វគ្រប់ហើយដល់យើងមានប្ដីមានកូនទៀតគាត់ក៏នៅមើលថៃយើងដែរ
ពេលដែលខ្ញុំឈឺដេកពេទ្យអញ្ចឹងគាត់មើលថៃកូនខ្ញុំមើលអីទៅមើលខ្ញុំនៅពេទ្យមើលថៃទាំខ្ញុំជាមួយប្ដីខ្ញុំហ្នឹង ដូចថាគាត់ស្រលាញ់កូនហាំ...គាត់អត់ចង់ឱ្យកូនទៅណាទេ
គាត់សុខចិត្តលះបង់ពេលវេលាគាត់ដើម្បីមើលថៃឱ្យយើងហា។

កៈ ចាសអញ្ចឹងអ្នកមីងអ្វីដែលជាការចងចាំបំផុតជាមួយម្ដាយរបស់អ្នកមីង
អ្នកមីងចាំអីគេជាងគេ?

ខៈ ខ្ញុំរកនឹក។

កៈ នូវទង្វើរអ្វីដែលអ្នកមីងគិតថាស្រលាញ់ម្ដាយរបស់អ្នកមីងដក់ជាប់នៅក្នុងដួងចិត្តជាងគេ

អញ្ចឹងហាំ??

ខៈ អារម្មណ៍ខ្ញុំគិតថានៅពេលដែលខ្ញុំឈឺធ្ងន់
ពេលខ្ញុំគេងអត់ដឹងខ្លួនអីគាត់មកអោបខ្ញុំគាត់ថៃគាត់ជូតទឹកក្ដៅដាក់ទឹកត្រជាក់ឱ្យខ្ញុំហើយខ្ញុំគិតថាអារម្មណ៍ខ្ញុំ
គាត់មានអារម្មណ៍ថាស្រលាញ់យើងមើលយើងទោះយើងមានប្ដីក៏ដោយមានកូនក៏ដោយក៏គាត់នៅមើលថៃយើងខ្ញុំគិតថាខ្ញុំក៏អត់បានសងគុណគាត់វិញដែរព្រោះខ្ញុំអត់បានមើលថៃទាំគាត់ដូចគាត់មើលថៃទាំខ្ញុំដល់ពេលគាត់ជិតស្លាប់នេះ។

កៈ ម៉េចបានអញ្ចឹងមីង?

ខៈ ព្រោះថាខ្ញុំនៅផ្ទះផ្សេងហើយប្អូនក៏នៅជាមួយគាត់ ប្អូនខ្ញុំគេមើលថៃ
អាពៅហ្នឹងមើលថៃគាត់ជិតដល់ជាង
យកទៅពេទ្យអញ្ចឹងគេមើលថៃទាំគាត់រហូតដល់គាត់ផុតហើយខ្ញុំកាលហ្នឹង ខ្ញុំនៅផ្ទះ។

កៈ ចាស!

ខៈ
វាអញ្ចឹងហើយមានអនុស្សាវរីយ៍ថានឹកឃើញចំណុចកន្លែងហ្នឹងមួយដែលខ្ញុំអត់បានសងគុណនៅទង្វើគាត់បានធ្វើចំពោះខ្ញុំហាំ...គ្រាន់ថាគាត់ចិញ្ចឹមយើងពីតូចងបង្កើតយើងមកដឹងហើយតែអាពេលដែលយើងឈឺយើងមានប្ដីមានកូនហើយ គាត់នៅតែមើលថៃយើងទៀត
ចាសហ្នឹងហើយកន្លែងហ្នឹង។

កៈ ហ្នឹងហើយគាត់ល្អមែនទែនមីងណោះ?

ខៈ ចាសហ្នឹងហើយ។

កៈ ចាសអញ្ចឹងអ្នកមីងសម្រាប់ឪពុកអ្នកមីងវិញគាត់កើតនៅថ្ងៃខែឆ្នាំណាដែរវិញ?

ខៈ សម្រាប់ប៉ាខ្ញុំកើតនៅឆ្នាំ ១៩២០ គេអត់ប្រាប់ថ្ងៃខែកំណើតអត់ដឹងទេចាស។

កៈ អញ្ចឹងគាត់កើតនៅភូមិឃុំអីគេដែរអ្នកមីង?

ខៈ គាត់កើតនៅជាមួយគ្នាហ្នឹងនៅឃុំចាក់អង្រែ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលហ្នឹងចាស។

កៈ អឺ...អញ្ចឹងមីងចាំថាឆ្នាំខ្មែរគាត់កើតឆ្នាំសត្វអីគេវិញឪពុក។

ខៈ ចុម...ឆ្នាំអីចេះរកនឹកសិន អត់ចាំទេ។

កៈ អត់ស្មានត្រូវអីគេខ្លះទេហ៎?

ខៈ ព្រោះគាត់ គាត់ស្លាប់នៅជំនាន់ប៉ុល ពត នៅឆ្នាំ...ឆ្នាំគាត់៦៧អាយុ
គុណបូកមើលហ៎ា...ឆ្នាំអីហ៎ា។

កៈ អញ្ចឹងអ្នកណាគេចង់ដឹងឱ្យគាត់គុណ បូក
តាមខ្លួនគាត់ទៅណែស។ចាសអញ្ចឹងអ្នកមីងតើអ្នកមីងចាំអនុស្សាវរីយ៍អីខ្លះជាមួយឪពុករបស់
អ្នកមីងទៅ គាត់ជាមនុស្សយ៉ាងម៉េចដែរឪពុករបស់អ្នកមីង?

ខៈ ចាសគាត់ ខ្ញុំដឹងក្ដីធំគាត់ចាស់ហើយណាស់ គាត់អាយុ៥០ ៦០ហើយ គាត់ចំណាស់ហើយ
ចាសហើយប៉ុន្តែប៉ាខ្ញុំដូចខ្ញុំនិយាយអញ្ចឹងថាកូនស្រីតែមួយគាត់ជំទើរអញ្ចឹង
ទៅណាក៏ទៅដែរឱបយកទៅហើយអាពៅក៏ស្រលាញ់
អាបងទើបស្រីបងគាត់ស្រលាញ់ជាងគេបំផុតកូនថីនាងអ្នកណាមួយមិនស្គាល់។

កៈ ចាស!

ខៈ គេហៅស្រីឆ្នាស់ គេហៅអាស្រីៗ មានស្រីទៀតទៅបានខ្ញុំ ស្រីធំអញ្ចឹងទៅចាស។

កៈ ចាសហ្នឹងហើយ។

ខៈ ហើយគាត់ប្រវត្តិគាត់គ្រូ ខ្ញុំមានអារម្មណ៍ថាគាត់ខំចិញ្ចឹមកូនទោះជាគាត់អាត្រែតចាស់
ប៉ុណ្ណឹងហើយក៏ដោយក៏នៅតែខំប្រឹងចិញ្ចឹមកូនដើម្បីបណ្ដុះកូនឱ្យរៀនហ៎ា...កូនណាមួយក៏
ត្រូវតែរៀន រៀនរហូត គ្រាន់តែសៀវភៅមួយទូ រៀនយប់ឡើងហៅកូនមករៀន
ក្រោមអាហ្នឹងយើងអត់មានចង្កៀងយើងហ៎ា...អាចង្កៀងប្រេងកាតហា។

កៈ ចាស!

ខៈ ដាក់អាធំហ្នឹងមកអង្គុយរៀនឱ្យកូនអង្គុយរៀនគ្រប់គ្នា។

កៈ គាត់អ្នកបង្រៀនអញ្ចឹងទៅ?

ខ៖ ចាសគាត់អ្នកបង្រៀនហើយរាល់ថ្ងៃសៅរ៍ឡើងទៅសូត្រធម៌ ឱ្យទៅថ្វាយបង្គំព្រះទាំងអស់បត់ជើងថ្វាយបង្គំព្រះរួចហ្មំ...ពេលថ្វាយបង្គំព្រះចប់ដឹកកូនមួយអ៊ីម៉កទៅមើលកុនរាល់ថ្ងៃសៅរ៍គាត់សម្រាកការងារគាត់។

ក៖ ចាស!

ខ៖ ទាំងអស់កូន។

ក៖ ហ្នឹងហើយ។

ខ៖ ចាសគាត់ស្រលាញ់ទាំងអស់។

ក៖ គាត់ចេះផ្តល់ពេលវេលាក្តីស្រលាញ់។

ខ៖ ចាស!

ក៖ គាត់បែកចែកបានល្អណាស់មីងហោ៎?

ខ៖ ចាស!

ក៖ មីងចំណុចកន្លែងមួយណាដែលអ្នកមីងស្រលាញ់ឪពុកអ្នកមីងជាងគេទៅ?

ខ៖ ខ្ញុំបើស្រលាញ់គាត់ជាងគេត្រង់ថាចេះតស៊ូចិញ្ចឹមកូនជិត១០នាក់ទាំងប្រពន្ធទាំងកូន។

ក៖ ចាស!

ខ៖ បើនិយាយទៅគាត់រកចិញ្ចឹមម្នាក់ឯង កូនទៀត កូនចិញ្ចឹមក៏មានមកនៅគ្រប់គ្រងទាំងអស់ហើយចិញ្ចឹមរ៉ាប់រងទាំងអស់រហូតដល់ពួកគេមានការងារធ្វើគ្រប់គ្នាបានគាត់ប្រលែងទៅ ហើយគាត់ទទួលផលពីគេខ្លះដូចថាគេជូនប៉ាប៉ុណ្ណេះទៅគេទិញអង្ករមួយបាវទៅមួយខែអី  អញ្ចឹងហា។

ក៖ ចាស!

ខ៖ ចាសហ្នឹង។

ក៖ តាមអញ្ចឹងទៅ។

ខ៖ ចាសហ្នឹងហើយ។

ក៖ អញ្ចឹងអ្នកមីងដូចជាគាត់មានប្រពន្ធមិន៣នាក់មីងហោ?

ខ៖ ចាស!

ក៖ អញ្ចឹងតើ៣នាក់ហ្នឹងគាត់យក ម្ដងទាំង៣ឬមួយក៏គាត់លែងមួយបានចូលមួយ?

ខ៖ ទេលែង។ដូចប្រពន្ធទី១ខ្ញុំអត់បានដឹងតែគ្រាន់តែថាឮចាស់ៗនិយាយតគ្នាថាលែង។

ក៖ ចាស!

ខ៖ ដូចថាគេអ្នកមានគេឆ្នាស់ ដល់ហើយម្ដាយគាត់ក៏ឆ្នាស់ដែរអត់ត្រូវគ្នាទេ ត្រូវតែលែងអត់មានកូនទេ
ដល់ទី២ហ្នឹងគាត់បានកូនប្រុសមួយគាត់ស្លូតគាត់ចេះបម្រើប៉ាខ្ញុំផ្គាប់ផ្គន់សព្វគ្រប់តែដល់គ្រាន់តែគាត់កូនខ្ចីហើយគាត់ងងឹតភ្នែក ងងឹតភ្នែកទៅគាត់ក៏សុំប៉ាទៅរៀនធម៌ហើយ
ព្រោះអីដូចថាគាត់ងងឹតភ្នែកគាត់មានជំនឿថាទៅរកធម៌ទៅមុខទៅណាស់។

ក៖ ចាស!

ខ៖ គាត់ទៅ សំណាក់ធម៌គាត់នៅស្រុកកោះឧញ៉ាតីនេះ។

ក៖ ហ្នឹងហើយ។

ខ៖ ចាសប៉ុន្តែនៅផ្ដល់លុយកាក់ទៅចិញ្ចឹមរាល់ខែ។

ក៖ ចាស!

ខ៖ ហើយហ្នឹងបងប្រុសខ្ញុំមួយកូនគាត់ហ្នឹង ហ្នឹងក៏គាត់ស្លាប់នៅអាពតដែរ។

ក៖ ចាដ!

ខ៖ ហើយបានប្រពន្ធទី៣ម៉ាក់អ៊ុំខ្ញុំហ្នឹងគាត់បានកូន៤នាក់សុទ្ធតែប្រុស។

ក៖ ចាស!

ខ៖ ហើយស្លាប់នៅប៉ុល ពតទាំងអស់
ចាសវ៉ៃចោលទាំងអស់បានមកម្ដាយខ្ញុំបានកូន៦នាក់។ក៖ ចាស!

ខ៖ ៦នាក់ស្លាប់ បងប្រុសខ្ញុំមួយហ្នឹងនៅ ខ្ញុំហើយនិងប្អូនខ្ញុំហ្នឹងនៅទាំងអស់។

ក៖ ចាសអញ្ចឹងម្ដាយអ្នកមីងជាប្រពន្ធទី៤របស់គាត់ឬជាប្រពន្ធទី៣?

ខ៖ ចាសជាប្រពន្ធទី៤។

ក៖ ហ្ហ៎...តា!

ខ៖ ប្រពន្ធចុងតា។

ក៖ ចាស!

ខ៖ ប្រពន្ធហ្នឹងមិនមែនថាយកមកមិនមែនលែងទេណាដូចថាគាត់សុំលែង សុំលា ដូចមិនលែងទេគ្រាន់តែថាគាត់យាយហ្នឹងគាត់ទៅគាត់ធ្វើអីមិនកើតអញ្ចឹងហា។

ក៖ ចាស!

ខ៖ ដល់ហើយមកម៉ាកអ៊ុំខ្ញុំគាត់ចុះទៅបេសកម្មតាមខេត្តអញ្ចឹងគាត់ឃើញម៉ាកអ៊ុំខ្ញុំហ្នឹង អឺ...ធម្មតាអ្នកស្រែឃើញអញ្ចឹងទៅគាត់ស្រលាញ់ទៅក៏រៀបការនៅនឹងស្រែហ្នឹង មកហើយអ៊ុំខ្ញុំហ្នឹងកូនអ្នកមានស្រុកស្រែ កូនស្រីតែមួយទៀតនិយាយពីមាសមកទាំងកាបង់ ហ្នឹងគាត់និយាយទេណាស់។

ក៖ ចាស!

ខ៖ ហ្នឹងខ្ញុំនិយាយតាមគាត់ទេ ភរតាមគាត់ កាបង់យកមកខ្សែជំនាន់ពាក់ឈៀងពាក់អីពីដើមហា...ហើយយកមកនៅផ្ទះយកមកនៅស្រុកភ្នំពេញយើងទៅ ហើយដល់យាយគាត់កញ្ជើផ្លុះនិយាយអញ្ចេកគាត់ដូចថាប៉ាខ្ញុំចុះទៅខេត្តអញ្ចឹងទៅឃើញម៉ាក់ខ្ញុំទៀតហើយ ហ្នឹងខ្ញុំនិយាយឱ្យអស់កេរ្តិ៍ហ្នឹងហ៎។

ក៖ ចាស!

ខ៖ ហ្នឹងហែកកេរ្តិ៍ខ្លួនឯងហ្នឹងហា...ឃើញម៉ាក់ខ្ញុំទៀតអញ្ចឹងគាត់អាណិតព្រោះម៉ាក់ខ្ញុំគាត់វេទនាណាស់គាត់កូនអ្នកក្រហ្ហ៎...។

ក៖ ចាស!

ខ៖ ឪពុកដើររកស៊ីកាប់អុសកាប់អីតាមព្រៃចាំជិះទូកហ៎...ចេវទូកមិនមែនយួនខ្មែរយើងតែគ្រាន់ថាចុះពីដើមចេះរបៀងចេះអាគមអីជីតាខ្ញុំហ្ហ៎...ជិះទូកចេវទូកតាមព្រៃកាប់អុសយកមកលក់ហើយគាត់ចេះតែមកតាមឪពុកគាត់តាមម្ដាយអញ្ចឹងទៅម្ដាយខ្ញុំហ្នឹងហ៎...ហើយដល់ពេលពេញក្រមុំ

អញ្ចឹងទៅគេហៅឱ្យមកនៅជាមួយគេដូចថាអ្នកមានហ្នឹងគេហៅឱ្យមកនៅជួយធ្វើការផ្ទះគេអញ្ចឹងហា...ធ្វើហើយអញ្ចឹងប៉ាខ្ញុំគាត់ដូចផ្លាស់ទៅកន្លែងកំពង់ចាមហើអីទេ អាហ្នឹងខ្ញុំគ្រាន់ឮប្រវត្តិគាត់និយាយគាត់ថាឃើញម្ដាយខ្ញុំហ្នឹងគាត់ពេញចិត្តហើយគាត់ក៏ស្រលាញ់
ស្រលាញ់ហើយគាត់និយាយជាមួយម្ចាស់ផ្ទះអីអញ្ចឹងយកគាត់មកនៅភ្នំពេញណេះហើយយាយខ្ញុំម៉ាក់អ៊ុំខ្ញុំនេះគាត់ខឹងគាត់ គាត់ខឹងគាត់ខឹងគាត់ហា...ឈ្លោះគ្នាដែរហ្នឹងហា។

ក៖ ចាស!

ខ៖ យកមកម្ដាយខ្ញុំគាត់គំនិតគាត់ក្រប៉ុន្តែគាត់មានគំនិត។

ក៖ ចាស!

ខ៖ ដូចថាគាត់ចេះទុកដាក់សព្វ គ្រប់ផ្ទះសម្បែងអីហា
រែកទឹកពុះអុសទាំងអស់ជំនាន់ហ្នឹងមានទឹកណា។

ក៖ ចាស!

ខ៖
ហើយដល់ហើយយាយគាត់ចេះខឹងគាត់ចេះតែយកលុយអាពីកេរ្តិ៍គាត់មកយកទៅដើររកគ្រូហ្ន៎...រកគ្រូស្នេហ៍រកគ្រូអីគ្រប់សព្វទៅណាស់។

ក៖ ចាសហ្នឹងហើយ យីតាអញ្ចឹងអ្នកមីងតើពេលហ្នឹងឪពុកអ្នកមីងគាត់ធ្វើជាអីគេដែរ?

ខ៖ គាត់ធ្វើ កាលហ្នឹងគាត់ធ្វើនៅក្នុងក្រសួងសុរិយោដី។

ក៖ ហ្ន៎...!

ខ៖ គាត់ធ្វើការនៅហ្នឹង។

ក៖ ចាស!

ខ៖ ចុះវាស់ដីចុះវាស់អីតាមខេត្តអញ្ចឹងទៅណាស់។

ក៖ ហ្ន៎...សម័យមុន។

ខ៖ ចាស!

កៈ អញ្ចឹងគាត់អ្នកចេះដឹងខ្លាំងណាស់អំណោះ?

ខៈ ហ្នឹងហើយ។

កៈ ហ្នឹងហើយ អញ្ចឹងអ៊ុំចូលដល់ជីដូនជីតារបស់អ៊ុំវិញម្តង តើអ៊ុំចងចាំថាតឡូវខាងឪពុកសិនអ៊ុំចាំថាតាហើយនឹងយាយអ៊ុំគាត់ឈ្មោះតាអីយាយអីអត់?

ខៈ អឺ...ខាងឪពុកខ្ញុំឈ្មោះអឺ...ហ៊ឺ...អញភ្លេចហើយពៅហា...ចាសឈ្មោះយាយលឿងហើយតាតាសុខ។

កៈ ចាសចាំត្រកូលគាត់ទេអ្នកមីង?

ខៈ អត់ចាំទេ ចាំតែតាលឿង យាយសុខ។

កៈ អ្នកមីងមានដឹងថាគាត់កើតថ្ងៃខែឆ្នាំកំណើតរបស់យាយនៅឯណាអត់?

ខៈ អត់ដឹងទេ។កាលខ្ញុំកើតមកអត់ទាន់គាត់ទេ។

កៈ ដឹងថាគាត់ស្លាប់នៅក្នុងជំនាន់អីគេទេ?

ខៈ ស្លាប់នៅក្នុងជំនាន់សីហានុហ្នឹងឯង។

កៈ មុនលន់ នល់ទៅទៀតអី?

ខៈ មុនលន់ នល់ទៀត។ចុះយើងខ្ញុំកើតនៅក្នុងជំនាន់មុនសីហានុហើយ។

កៈ ចាស!

ខៈ ដល់ពេលគាត់ស្លាប់តាំងពីមុនហ្នឹងទៀតហ្ន៎...ជំនាន់ហ្លួងសុវណ្ណាកោត សុវណ្ណាអីនោះព្រោះអីស៊ីសុវត្ថិចាសខ្សែ គាត់ខ្សែហ្នឹង។

កៈ ហ្ន៎...!

ខៈ យាយខ្ញុំម្តាយប៉ាខ្ញុំគាត់ត្រូវក្សួយហ្លួងស៊ី សុវត្ថិហ្នឹង។

កៈ អញ្ចឹងជាប់ខ្សែស្តេច?

ខៈ ចាសខ្សែ តែខ្សែយើងហ្នឹងវាដាច់ធឹងហើយ។

កៈ អត់ទៅជាប់?

ខ៖ ចាស!

ក៖ អញ្ចឹងអ្នកមីងដូចអ្នកមីងកើតអត់ទាន់គាត់ហ្មង?

ខ៖ អត់ទាន់សោះ។

ក៖ បិទជិតឆឹងហ្មង?

ខ៖ ឃើញតែរូបថតមួយទេ។

ក៖ ចាសហើយដែលលោកប៉ាអ្នកមីងបានដំណើររឿងប្រាប់ពីជីវិតរបស់តាយាយថាគាត់គឺជាមនុស្សម៉េចដែរអញ្ចឹងអត់ ធ្លាប់ឮអត់?

ខ៖ គ្រាន់តែធ្លាប់ឮគាត់និយាយថា បើតាអត់ដែលឮប៉ុន្តែគ្រាន់តែថាគាត់គឺជាជាងទងជាងមាស។

ក៖ ចាស!

ខ៖ គាត់ធ្វើមាសហា...ចាសហើយចរិកខ្ញុំអត់ដឹងទេ
ដឹងតែមុខរបរគាត់ហើយបើយាយខ្ញុំដឹងពីចរិកគាត់ព្រោះគាត់ឆ្នាស់ គាត់កាច
ថៅៗអីគាត់វ៉ៃរាបទាំងអស់
គាត់ថាគាត់កាចហ្មងតែពេលណាគាត់មានអីអញ្ចឹងទូលគាត់ទូលជំនាន់ពីដើមគាត់ទូលមានផ្លែឈើអី គាត់ទូលទៅហៅថៅទៅតាមហើយ ទៅតាមចូលទៅវាំង
វាំងទៅយកផ្លែឈើអីទៅជូនសាច់ឈាមគាត់ហ្នឹងហើយ។

ក៖ ហ្ហ៎...ខ្សែស្ដេច។ចាសអញ្ចឹងអ្នកមីងសម្រាប់ចូលដល់ខាងម្ដាយវិញម្ដង
អ្នកមីងចាំឈ្មោះតាអីយាយអីអត់ខាងម្ដាយ?

ខ៖ ម្ដាយរបស់ម្ដាយខ្ញុំឈ្មោះយាយផង់ អត់ដឹងថានាមត្រកូលអីទេតែជីតាឈ្មោះអ៊ុំ។

ក៖ អ្នកមីងកើតទាន់គាត់២នាក់អត់?

ខ៖ ខ្ញុំអត់ទាន់ទេតា អត់ទាន់ឈឹង ហើយបើយាយខ្ញុំឃើញស្រពិចស្រពិលរូបថតស្រពិចស្រពិលទេព្រោះគាត់ធ្លាប់មកលេងខ្ញុំម្ដងនៅផ្ទះកាលខ្ញុំនៅតូចហ្នឹងហា...ខ្ញុំឃើញគាត់ស្រពិចស្រពិលទេអត់ចាំគាត់ច្បាស់ទេ។

ក៖ ចាស!

ខ៖ តែគាត់ខ្លាចប៉ាខ្ញុំណាស់។

ក៖ ម៉េចអញ្ចឹងវិញ?

ខ៖ ខ្លាចដោយសារគាត់អ្នកដូចថានាម៉ឺនអញ្ចឹងហា។

ក៖ ចាស!

ខ៖ ហើយគាត់អ្នកក្រ ម្ល៉ោះហើយមកលេងផ្ទះកូនប្រសារអីអញ្ចឹងទៅគាត់ចេះតែខ្លាចទៅណាស់ហើយគាត់ហូបស្រាទៀតយាយហ្នឹង ហើយប៉ាខ្ញុំអត់ចូលចិត្តទេ។

ក៖ ចាស!

ខ៖ ហើយគាត់អត់សូវហ៊ានទេ ហើយគាត់នៅឆ្ងាយនៅជាមួយកូនធំៗគាត់ បងគាត់ទៅហើយបានគាត់ស្លាប់ទៅស្លាប់ទៅចាស។

ក៖ ចាសហើយអ្នកមីងដឹងថាយាយគាត់ស្លាប់ជំនាន់អីគេអត់?ឆ្នាំណាអត់?

ខ៖ មើលយាយខ្ញុំអត់ដឹងថាស្លាប់ជំនាន់ណាឆ្នាំណាទេនេះ អត់ដឹងថាគាត់ស្លាប់ប៉ុន្តែស្លាប់ក្នុងពេលជំនាន់ដូចជាលន់ នល់ហើយហ៎ោ...បែកគ្នាហ្នឹងហ៎ា...បែកបាក់គ្នាពេលរត់គ្រណាត់ ត្រណែងពេលលន់ នល់ចូលមកបែបស្លាប់ពេលហ្នឹងហ៎ា។

ក៖ ចាស!

ខ៖ ព្រោះពេលបែកគ្នាគាត់នៅក្រចេះលើ ទៅហើយខ្ញុំនៅភ្នំពេញណោះ។

ក៖ អំឡុងពេលទម្លាក់សម្តេចអញ្ចឹងទៅប្រទេសជាតិច្របូកច្របល់មីង?

ខ៖ ប្រទេសជាតិច្របូលច្របល់ ចាសហើយបែកខ្ញែកគ្នាអស់។

ក៖ ចាសហើយចុះតាអ្នកមីងធ្លាប់ឮអីពីតាខាងម្តាយអត់?

ខ៖ តាអុំហ៎ោ...ដូចខ្ញុំបានប្រាប់អញ្ចឹងថាគាត់រកស៊ីកាប់អុស។

ក៖ ចាស!

ខ៖ ជិះទូកកាប់អុសតាមព្រៃហ្នឹងនាំកូននាំប្រពន្ធហ្នឹងរកស៊ីតែអញ្ចឹង កាប់អុសយកមកលក់ ហើយគាត់ដូចថាគាត់ចេះរបៀង ចេះអី ចេះចងមាត់ពស់ ពន្លៃចងមាត់ពស់អី ហើយគាត់ចង់ចាក់អាប៉ោង គាត់ចូលព្រៃតែមួយសន្ទុះបោចវល្លិមកគាត់ចងចង្កេះគាត់ទៅចាក់អាប៉ោង ហើយ។

ក៖ ម៉េចអញ្ចឹង?

ខ៖ អាហ្នឹងអាប៉ោងចេញលេខប៉ុន្មានអាវល្លិហ្នឹងចាក់ចង្កេះគាត់ប៉ុណ្ណឹង។

ក៖ ហ្ហ៎...!

ខ៖
អាហ្នឹងខ្ញុំឮសួរម៉ែខ្ញុំនិយាយហាំ...ហើយបើថាព្រាយហោះវិញហាំ...ម៉ែខ្ញុំគាត់ថាហៅម៉ែមីអីទេ ហៅម៉ែមីកាលង់ កាលង់ងែងមើលហ្ហ៎...ព្រាយអញចងឱ្យមើលហាំ...ទៅគាត់ចងគាត់សូត្រ អាគមគាត់ហ្នឹងហាំ...គាត់ធ្វើដូចឯងថ្ពុកដូចជាប់ឆ្អឹងនៅហ្នឹងឱ្យមើលទៅ។

ក៖ ឃើញហ្មង?

ខ៖ ឃើញភ្លើងដុំហ្នឹងហោះហ្នឹងហាំ...ហ្នឹងហើតនៅហ្នឹងហ្មង គាត់ថាស្រាយវិញស្រាយទៅគាត់ថាវាអត់ហ៊ានធ្វើអីយើងអីដែរគាត់ចេះរបៀងច្រើន។

ក៖ ចាស!

ខ៖ ប៉ុន្តែគាត់ស្លាប់ទៅក៏កប់ទៅជាមួយអត់មានចែកកេរ្តិ៍ថៅណាមួយ។

ក៖ គាត់រៀនមកពីអ្នកណាគេវិញអ្នកមីងណោះ តគ្នាអី?

ខ៖ ខ្ញុំអត់ដឹងដែរ តគ្នាពីដូនតាមក ព្រោះយើង២ ៣ជំនាន់ហើយហ្នឹង។

ក៖ ចាសដូចជំនាន់មុនមន្តអាគមន៍សាហាវណាស់មីងណោះ?

ខ៖ ចាសមើលយើងមើលរឿងមើល។

ក៖ តែដល់ពេលសម័យឥឡូវដូចជាសាបរលាបអីអស់ហើយមីង?

ខ៖ សាបអស់ហើយចាសបើដូចរឿងអាបអីឯងឃើញទេថា អាបឥឡូវមានមិនថាអត់ទេហិ...មានហិ...។

ក៖ ចាស!

ខ៖ អាប ធ្មប់មាននៅតាមស្រុកស្រែជនបទមាន យើងភ្នំពេញអត់មាន មិនបាច់និយាយណាទេគ្រាន់តែនៅកន្លែងកូនខ្ញុំធ្វើការនៅឧដុង្គយើងនេះ។

ក៖ ចាស!

ខ៖ ភ្នំប្រសិទ្ធយើងនេះមានអាប។

ក៖ ឃើញហ្មងមីងហេ?

ខ៖ បើសន្តិសុខ សន្តិសុខពួកអ្នកយាមនៅស្ថានីយ៍កូនខ្ញុំហ្នឹងពេលយប់អញ្ចឹងវាជិះប្រត្រុយក្រឡឹងពន្ធ័ជុំវិញស្ថានីយ៍គេដើរយាមអញ្ចឹងហា។

ក៖ ចាស!

ខ៖ ដល់ហើយភ្លៀងព្រិចៗឃើញភ្លើងភ្លុងៗ នៅឯស្រែហ្នឹងហា...ដល់ហើយវារកក្តាមរកខ្យងអីវាស៊ីកង្កែបអីអញ្ចឹងទៅណាស់។

ក៖ ចាស!

ខ៖ ហើយដល់គាត់ស្រែកថាអ៊ើយ...អាណាធ្វើអីហ្នឹង?ប្រចាំងពិលភ្លែតស្រាប់តែវាស្រែកមកវិញថាខ្ញុំហួសចិត្ត វាស្រែកមកវិញថាម៉េចឯងចង់ងាប់ហេ។

ក៖ អើស...!

ខ៖
អាបហ្នឹងហា...ចាសហ្នឹងហើយវាស្រែកមកអញ្ចឹងហា...ពួកហ្នឹងសុទ្ធតែពួកទាហានខ្មែរក្រហមហា...ដែលធ្វើសន្តិសុខនៅកន្លែងភ្នំប្រសិទ្ធនៅកន្លែងឧដុង្គហ្នឹងហា។

ក៖ ចាស!

ខ៖ ពួកហ្នឹងនៅហ្នឹងធ្វើសន្តិសុខវាអត់ខ្លាចទេណាស់វាធ្លាប់ដើរព្រៃ។

ក៖ អូយ...!

ខ៖ ថាម៉េចឯងចង់ងាប់ហេ...គាត់សួរអាណាហ្នឹងគាត់ចុចពិលទៅហា។

ក៖ ហើយឃើញមុខទេមីង?

ខ៖
ខ្ញុំអត់ដឹងថាគាត់ឃើញឬក៏អត់ទេគ្រាន់តែប្អូនកូនខ្ញុំវានិយាយប្រាប់ខ្ញុំថាសន្តិសុខនិយាយប្រាប់វាអញ្ចឹង ហេ...ឥឡូវមានហា...នៅស្រុកគ្រាន់តែថាអាដីហ្នឹងមានធ្មប់ដែរហើយនៅខាងព្រៃកដរនៅកោះគរ។

ក៖ ចាសនៅក្បាលកោះគរមានធ្មប់។

ខ៖ មានធ្មប់ ពួកហ្នឹងហា...បើវាអត់បានធ្វើយើងវាពិបាកវាងាប់ វាឈឺខ្លួនវាដែរ។

ក៖ អូយ...!

ខ៖ សុទ្ធតែធ្វើកូនខ្ញុំថាដីមួយផ្ទះមួយអញ្ចឹងហា...ដូចថាផ្ទះមួយហ្នឹងមានសង់អាលើឈើអាក្រោមថ្មហើយដាក់លក់ម្ចាស់ណាមួយទៅទិញនៅអត់បានប៉ុន្មានទេងាប់ទៅនៅបានប៉ុន្មានងាប់ហើយស៊ីបានតែប្រុសដូចថាឱ្យតែប្តីឱ្យតែមនុស្សប្រុសគឺថាឱ្យតែទៅនៅផ្ទះហ្នឹងគឺឈឺ មិនដឹងថាម៉េចឱ្យតែទៅប្តីប្រពន្ធគឺថាផ្ទះហ្នឹងផ្ទះឃាយអនាម័យកន្លែងយើងទេហើយដល់ឃាយហ្នឹងគាត់ធ្វើទៅដូចនៅទៅវាអត់ស្រួលហា...ប្តីគាត់ចេះតែឈឺហើមរីងរៃរកអត់ដឹងមុខថាឈឺអី គាត់លក់ទៅ គាត់លក់ឱ្យគេតហើយគេទិញតទៅប្តីបានទៅហ្នឹងអាអ្នកទិញតវាឈឺអញ្ចឹងទៀតហើមមិនដឹងមុខមិនដឹងមាត់ទៀតហើយគេក៏ឈប់លក់អញ្ចឹងទៀតលក់ផ្ទះហ្នឹងចោលអ្នកទិញ ក្រោយហ្នឹងអញ្ចឹងទៀតដល់ឥឡូវមានអ្នកណាហ៊ានទិញចង់ថោកអីម៉េចក៏អត់មានអ្នកណាហ៊ានទិញដែរ។

ក៖ ឥឡូវហ្នឹង?

ខ៖ ចាសគេហៅដីអាថាន់ម៉េចហា។

ក៖ សាហាវណាស់មីងណេះ?

ខ៖ ដីហើយលក់ថោកទៀតមានអ្នកណាហ៊ានទិញទេ។

ក៖ ហើយរើផ្ទះហ្នឹងចោលហ្មងទៅថី?

ខ៖ អញ្ចឹងបានថាខ្ញុំថារើចោលទៅ ហើយយើងធ្វើផ្ទះថ្មីទៅ ហើយផ្ទះហ្នឹងគេទិញទិញហើយគេធ្វើណាស់អាអូន គេធ្វើចុះគេអ្នកមានភ្នំពេញដែរនោះគេទិញ

ទិញហើយរូសរ៉ែហើយធ្វើឱ្យ ស្អាតទៅនៅអត់បាន
នៅអត់បានគេទុកចោលហ្មងហើយមកនៅភ្នំពេញវិញទៅ។

ក៖ ចាស!

ខ៖ ឥឡូវទុកនៅហ្នឹងទោះហៅគេទិញក៏អត់មានអ្នកណាគេទិញដែរ។

ក៖ ចាស!

ខ៖ ដល់តែអ្នកស្រុកអត់ដឹងអ្នកចម្ងាយអត់ដឹងហ្មង។

ក៖ អញ្ចឹងអ្នកមីងចូលដល់ក្រុមគ្រួសារអ្នកមីងតើក្រុមគ្រួសារអ្នកមីងរស់នៅលើទឹកដីហ្នឹង
ហា...ដែលអ្នកមីងរស់នៅសព្វថ្ងៃនៅចាក់អង្រែហ្នឹងយូរប៉ុណ្ណាហើយ?ឬក៏ទើបតែមករស់នៅជំនាន់ណាដែរ?

ខ៖ ខ្ញុំរស់នៅតាំងពីនិយាយទៅតាំងពីខ្ញុំកើតមក តាំងពីដូនតាមកនៅក្នុងទឹកដីកន្លែងហ្នឹង។

ក៖ ចាស!

ខ៖ តែគ្រាន់តែយើងដូរផ្ទះដូរទីតាំងវាអត់មានដូរទៅណោះ វាអត់មានដូរថានៅដីហ្នឹង
ម្ដុំហ្នឹងគ្រាន់តែថាដូរផ្ទះ។

ក៖ ចាស!

ខ៖ យើងរុះផ្ទះរុះអីសាងសង់ថ្មីអីអញ្ចឹងទៅ។

ក៖ ហ្នឹងហើយ!

ខ៖ កើតក៏នៅហ្នឹងរស់នៅសព្វថ្ងៃក៏នៅហ្នឹង តាំងពីដូនតាមករហូត។

ក៖
ចាសអញ្ចឹងអ្នកមីងតើអ្នកមីងមានសាច់ញាតិដទៃដែលរស់នៅក្រៅពីប្រទេសខ្មែរយើងអត់?

ខ៖ ខ្ញុំមានសាច់ញាតិច្រើនដែរហ្នឹង បង្កើតអត់មានមានតែជីដូនមួយ។

ក៖ ចាស!

ខ៖ មាន មានច្រើនសុទ្ធតែក្មួយ ។

ក៖ គាត់ទៅរស់នៅឯណាវិញ?

ខ៖ គេនៅអាមេរិច នៅកាលីហ្វ័រញ៉ា ។

ក៖ និយាយទៅនៅប្រទេសអាមេរិចហ្នឹងមីងណោះ?

ខ៖ ចាស!

ក៖
អញ្ចឹងអ្នកមីងចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់អ្នកមីងវិញម្តងតើស្វាមីរបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះ សរ សំអួន។

ក៖ ចាសអ្នកមីងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរ?

ខ៖ ខ្ញុំនៅជំនាន់ប៉ុល ពត។

ក៖ គេរៀបឱ្យ?

ខ៖ ចាសគេរៀបឱ្យយើងអត់ស្គាល់គ្នា យើងអត់ដែលមានស្គាល់គ្នាទេគេហៅយើងទៅសួរហ្នឹងហើយ ណែ...ខ្ញុំឱ្យមិត្តឯងណែ...ចាប់ដៃគូរប្តេជ្ញាជាមួយមិត្តនេះ មិត្តអូននេះនៅកងនេះកងនោះគេប្រាប់យើងហា...។

ក៖ ចាស!

ខ៖ ហើយយើងអត់ស្គាល់គ្នាផងហ្នឹង ហើយយើងម៉េចហ៊ាន ប្រកែកចាស។

ក៖ បើសិនប្រកែកម៉េចវិញទៅមីង?

ខ៖ បើប្រកែកគេរករឿងដែរហ្នឹង បាត់ខ្លួនឥឡូវហ្នឹង។

ក៖ អូ...អាចស្លាប់ទៀត។

ខ៖ ព្រោះអីប្តីខ្ញុំហ្នឹងគេហៅថាអារុនមិត្តភក្តិខ្ញុំ២នាក់ដៃគូរគ្នាអញ្ចឹងហា...ធ្វើការនៅក្នុងអាពតជាមួយគ្នាហ្នឹងហា...គេឱ្យមិត្តរុនហ្នឹងយកប្តីខ្ញុំហើយហៅមិត្តរុនសួរ មិត្តរុនថាគេថាគេអត់យកទេអត់យកទេគេថាចង់វ៉ៃចោលហ្មង ពូកែចុះគេផ្គូរផ្គងហើយមិនយកមិនបានគេលើកមកខ្ញុំ។

ក៖ ចាស!

ខ៖ ខ្ញុំអត់ប្រកែកខ្ញុំនឹកឃើញថាយើងធ្វើម៉េចមើលទៅចរិកគាត់ស្លូតបូតដែរប្តីខ្ញុំហា។

ក៖ ចាសហើយអញ្ចឹងក៏បានទៅ?

ខ៖ ចាសបានប្ដេជ្ញាជាមួយគ្នាហ្មងទៅ កាលហ្នឹងដូចប៉ុន្មានគូរទេណោះ ច្រើនណាស់។

ក៖ រកមុខឃើញហើយអ្នកគេរៀបឱ្យនៅជំនាន់អាពត។

ខ៖ ចាសអង្គុយអញ្ចឹងពាក់អាវខ្មៅសំពត់ខ្មៅ។

គ៖ ខ្ញុំចាំកាលរៀបការ៧០គូរ។

ក៖ អញ្ចឹងពេលរៀប៧០គូរអ្នកមីងណោះ?

ខ៖ ចាសចាស់ប៉ុន្មានក្មេងប៉ុន្មានអីទេ ហើយក្មេងដូចឃើញតែ៣គូរខ្ញុំទេណាស់។

ក៖ ចាស!

ខ៖ ក្រៅពីហ្នឹងសុទ្ធតែចាស់ៗមេម៉ាយ ពោះម៉ាយគ្រប់គ្នាហ្នឹងចាស។

ក៖ នៅក្នុងឆ្នាំប៉ុន្មានដែរមីងនៅក្នុងពេលជំនាន់អាពតហ្នឹង?

ខ៖ រៀបដូចជាជំនាន់បែក៧៧(១៩៧៧)ពៅហេ?

ក៖ ៧៩(១៩៧៩)បែក។

ខ៖ ៧៧(១៩៧៧)។

ក៖ ៧៧(១៩៧៧)រៀបការ?

ខ៖ ចាស៧៧(១៩៧៧)រៀបការ ដើមឆ្នាំ៧៧(១៩៧៧)ព្រោះអីចុងឆ្នាំ៧៧កើតអាញឹប ហេកើតអាញឹប៧៨(១៩៧៨)ទេ។

ក៖ ចាស!

ខ៖ ចាសហើយអញ្ចឹងខ្ញុំកើតទៅហើយខ្ញុំរៀបចំពី៧៧(១៩៧៧)។

ក៖ ចាសអញ្ចឹងអ្នកមីងតើដូចជាការរៀបការហ្នឹងដូចអ្នកមីងមានអារម្មណ៍ថាចូលចិត្តគាត់ខ្លះៗ នៅពេលអាពតហៅប្ដេជ្ញានឹងហា?

ខ៖
យើងអត់ដែលស្គាល់ចិត្តគាត់ទេគ្រាន់តែថាបានឃើញគេលួចប្រាប់អញ្ចឹងហា...ថានោះមិត្តមួយនោះដែលអង្គការគេរៀបចំឱ្យហ្នំ...។

ក៖ ចាស!

ខ៖ ហើយខ្ញុំចេះតែលួចមើលទៅណាស់ ចេះតែសម្គាល់មើលហើយគាត់ហ្នឹងអត់មានខ្វល់ទេ។

ក៖ ចាស!

ខ៖ ដើរឃ្វាលក្របីទៅហើយ អត់មានគិតជាមួយអ្នកណាទៅហើយដើររហូត។

ក៖ ហើយគាត់មានលួច...មីងមានដឹងថាគាត់ធ្លាប់លួចស្រលាញ់មីងអត់?

ខ៖ អត់ គាត់ក៏មិនដែលស្គាល់យើង យើងក៏មិនដែលស្គាល់គ្នា យើងអត់មានធ្វើការប្រលូកគ្នា ព្រោះអីគាត់ផ្នែកក្រុមឃ្វាលក្របីផ្សេង ខ្ញុំខាងចល័តដើរធ្វើការចាស។

ក៖ ចាស!

ខ៖ ដល់ហើយអត់ស្គាល់គ្នាទេព្រោះគាត់មូលដ្ឋានគេចូលចិត្តព្រោះគាត់ស្លូតធ្វើការងារល្អម្ល៉ោះហើយគេទាញយកទៅខាងឃ្វាលក្របីបានហូបច្រើនដូចថាបានបាយឆ្អែតអញ្ចឹងហា។

ក៖ ចាស!

ខ៖ គេអាណិតគេចូលយកគាត់ទៅធ្វើជាមួយអញ្ចឹងទៅ មូលដ្ឋានគេយកទៅជាមួយ។

ក៖ ចាសចុះអ្នកមីងពេលរៀបការហ្នឹងស្ថានភាពនៃការប៉ុល
ពតរៀបចំចាប់ដៃប្ដេជ្ញាហ្នឹងវាម៉េចដែរមីងអាចរៀបរាប់ប្រាប់បន្តិចមក។

ខ៖ ទៅគេកំណត់យើងថាថ្ងៃណាសម្រាប់យើងប្ដេជ្ញាអញ្ចឹងហា...គេហៅយើងឱ្យទៅស្លៀកពាក់ស្រួលប្រួលឃើញមានអាវខ្មៅសំពត់ខ្មៅបង់កក្រមាអីអញ្ចឹងទៅ កាត់សក់ការខ្លីអញ្ចឹងទៅ ហើយគេហៅទៅ គេប្រជុំគ្នាឱ្យយើងកាន់ទល់មុខគ្នាអញ្ចឹងហា...អង្គុយទល់មុខគ្នាអញ្ចឹងមួយគូរៗអញ្ចឹងហា...ហើយចាប់ដៃគ្នាអញ្ចឹងទៅហើយឱ្យយើងហ្នឹងឡើងប្ដេជ្ញាថាយើងស្រលាញ់គ្នាអស់មួយជីវិតអញ្ចឹងហា...ហ្នឹងហើយ
ហើយគេរួចគេមានបាយមួយស្ពកហ្នឹងដូចយើងដូចលោកឆាន់
លោកឆាន់រាល់ថ្ងៃដាក់ស្ពកមុខអញ្ចឹងហា...ទល់មុខគ្នាញ៉ាំបាយហ្នឹងទៅ។

កៈ ហ្នឹងហើយ។អញ្ចឹងហើយក៏ពេលហ្នឹងអត់មានក្រដាសស្នាមអីទេមីងហ៎?

ខៈ អត់ អត់មានអីទេ។

កៈ ប្ដេជ្ញាហើយ?

ខៈ ប្ដេជ្ញាហើយនៅមុខអង្គការហ្នឹង នៅអង្គការហ្នឹង មុខអង្គការហើយហ្នឹងគេទទួលស្គាល់ហើយហ្នឹង។

កៈ ហ្នឹងហើយ
ហើយដល់ពេលអញ្ចឹងចាប់ផ្ដើមមីងចូលចិត្តស្រលាញ់គាត់ពេលហ្នឹងមករហូតមកអញ្ចឹងហ៎?

ខៈ អារម្មណ៍ស្រលាញ់ដូចអត់មាន ពេលមុនដូចថារៀបការទទួលយកប្ដីហ្នឹងយកទាំងដូចថាអត់មានអារម្មណ៍គិតថាយកប្ដីអីទេណាស់។

កៈ ចាស!

ខៈ
ហែងយល់ទេថាយើងអត់មានចិត្តថាយើងអត់ចង់បានប្ដីដោយក្ដីស្រលាញ់យើងអីអត់ទេរបៀបដូចថាយកចេះតែយកយកទៅណាស់ ដូចថាឱ្យតែរស់អញ្ចឹងហា។

កៈ ចាស!

ខៈ ថាឱ្យតែរស់ទៅយើងចេះតែធ្វើតាមគេទៅ។

កៈ ចាស!

ខៈ ចាសហើយយើងក៏ប្រកបដែរបានប្ដីល្អដែរបាន។

កៈ ហេងហើយមីងហេងអាពតរកឱ្យត្រូវហេ?

ខៈ ហ្នឹងហើយ ខ្លះមកអញ្ចឹងទៅលែងគ្នា។

កៈ ល្អសើចមែនទែនដល់ពេលនេះហាមីងចាប់រើសឱ្យដោយមិនដឹងស្គាល់គ្នាហា។

ខៈ ចាសមិនដែលស្គាល់គ្នាទេ?

កៈ ចេះតែមានហ្មងលោកបងប៉ុល ពតនេះដូចជារកអីមកចម្លែកៗមីងណោះ?ចុះអ្នកមីងសម្រាប់ការសិក្សាការរៀនភាសាតើអ្នកមីងចេះអានហើយនឹងសរសេរភាសាខ្មែរបានល្អហើយច្បាស់ល្អអត់?

ខៈ ចាសរឿងថាអក្សរខ្មែរខ្ញុំបានច្បាស់ល្អណាស់។

កៈ ចាស!

ខៈ ព្រោះយើងរៀនបានកម្រិតខ្ពស់ដែរ ព្រោះខ្មែរខ្ញុំពូកែតែគ្រាន់តែឥឡូវវ័យប៉ុណ្ណោះហើយចេះតែភ្លេចភ្លាំងខ្លះហើយ។

កៈ ចាសហ្នឹងហើយចុះអ្នកមីងតើអើអ្នកមីងចេះភាសាអីក្រៅពីភាសាខ្មែរយើងអត់?

ខៈ ខ្ញុំអត់មានចេះអីគេទេអង់គ្លេសស្ទើរ អង់គ្លេសស្តាប់គេបានតិចតួច។

កៈ ចាស!

ខៈ បិបឺអី។

កៈ អ្នកមីងធ្លាប់រៀនពីមុនប៉ុន្មានឆ្នាំដែរភាសាអង់គ្លេស?

ខៈ ខ្ញុំអត់បានរៀនទេព្រោះយើងចេះបារាំងស្រាប់អញ្ចឹង យើងចេះតែកាត់យល់ៗទៅ។

កៈ ចាស!

ខៈ ចាសកាលធ្វើការជាមួយអង្គការខាងច្បាប់ហ្នឹង ខ្ញុំគេឱ្យខ្ញុំរៀនដែរ។

កៈ ចាស!

ខៈ ខ្ញុំរៀននៅស្អីកន្លែងនេះ នៅកន្លែងនេះភ្លេចហើយ។

កៈ នៅជិតស្ពានពេទ្យលោកសង្ឃហ្នឹងមែន?

ខៈ អត់ទេអាកន្លែងផ្លូវជិតសាលាចតុមុខហា...អាកន្លែងគេបាញ់ស្អី។

កៈ កែម ឡី?

ខៈ មែនទេ បាញ់នាងតារាចម្រៀងនោះហ្នំ...មួយទៀត។

កៈ ពិសិដ្ឋ ពីលីកា?

ខ៖ ដែលទៅយួន អឺ...ហ្នឹងហើយពៅ បញ្ញាពេជ្រ សាលាហ្នឹងគេឱ្យខ្ញុំរៀននៅហ្នឹង ហើយទៅអង្គុយរៀនជាមួយក្មេងតូចៗ។

គ៖ ពៅ បញ្ញាពេជ្រគេបាញ់នៅឯណា?

ខ៖ គេបាញ់នៅសាលាហ្នឹង។

ក៖ ហ្ហ៎...បញ្ញាសាស្រ្តហ៎?

ខ៖ មែនទេដូច អិល...ស្អីទេ ខ្ញុំភ្លេចហើយ។

ក៖ អត់អីទេ។អញ្ចឹងអ្នកមីងចេះភាសាបារាំងមែនទេ?

ខ៖ បារាំងអត់ចេះនិយាយទេតែគ្រាន់តែអាចមើលបាន។

ក៖ ហ្ហ៎...!

ខ៖ យល់ខ្លះព្រោះយើងភ្លេចអស់ហើយ។

ក៖ ចាសហ្នឹងហើយ។អញ្ចឹងអ្នកមីង ខ្ញុំចង់ដឹងអំពីខ្សែជីវិតរបស់អ្នកមីងតើអ្នកមីងធំឡើងហា...តើអ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំរៀនបានចូលមកថ្នាក់ទី៣ទំនើបហើយ។

ក៖ ចាស!

ខ៖ ឆ្នាំប្រលងឌីប្លូម តែខ្ញុំដោយសារបញ្ហាគ្រួសារដោយសារប៉ាខ្ញុំគាត់ឈឺអត់មានអ្នកណាផ្គត់ផ្គង់យើងហា...ម្ល៉ោះហើយខ្ញុំត្រូវឈប់ចាសហ្នឹងហើយទី៣ចាស់ហ្នឹង។

ក៖ ទី៣ចាស់ជំនាន់មុន?

ខ៖ ជំនាន់មុនឌីប្លូមហ្មង ប្រលងឌីប្លូម។

ក៖ អញ្ចឹងរៀនបានច្រើនដែរអ្នកមីងណោះ?

ខ៖ ចាសប្រលងឌីប្លូមទី៣ហ្នឹង យើងជាប់ឌីប្លូមចូលទី២។

ក៖ ចាស!

ខ៖ ទី២ចប់ហើយបានចូលទី១ ទី១បាក់អង ហ្អ៎...ជាប់បាក់អងបានចូលបាក់ឌុប ថ្នាក់ទីបញ្ចប់ ចាសវាមាន៣ក្រលាក់អញ្ចឹងកាលជំនាន់ហ្នឹង។

ក៖ ចាសចុះអ្នកមីងចាំថាអ្នកមីងរៀននៅសាលាបឋមសិក្សាណាអត់?

ខ៖ ខ្ញុំហេ...រៀនចល័តហ្មង ព្រៃកតាពៅក៏រៀន ក្រពើហាក៏រៀន តាខ្មៅក៏រៀន។

ក៖ ថ្នាក់បឋមហា?

ខ៖ ចាសបឋម ព្រោះគេដូរយើងរហូត។

ក៖ ហ្អ៎...!

ខ៖ គេថាហូ...ឥឡូវយើងខ្វះនេះ សាលានៅនេះខ្វះ មុនដំបូងខ្ញុំចូលតាខ្មៅ តាខ្មៅបឋមសិក្សាតាខ្មៅនេះ គេថាដល់ថាថ្នាក់ហ្នឹងវាពេញអស់ហើយគេត្រូវបញ្ជូនយើងទៅសាលាក្រពើហា ក្រពើហារៀននៅក្នុងកុដលោកទៀតហាមិនមែនរៀននៅក្នុងបន្ទប់សាលាទេ អត់មានសាលាទេកាលហ្នឹងវាពិបាកសាលាវាតិច ដល់រៀននៅក្នុងកុដលោកថ្នាក់ទី១១ហ្អ៎...កាលហ្នឹង រៀនចប់ទី១១បានគេថាហ្អ៎...យើងឡើងមក យើងឡើងមក រុញមកតាខ្មៅវិញ រុញមកតាខ្មៅវិញបានចូលទី៧ប្រលងចូលទី៦ហ្នឹងបានមកចូលអនុវិទ្យាល័យហ្នឹងបានគេរុញខ្ញុំទៅរៀននៅព្រៃកតាពៅវិញ។

ក៖ ចាស!

ខ៖ ចាស!

ក៖ ទៅចប់បឋមនៅព្រៃកតាពៅ។

ខ៖ ព្រៃកតាពៅហ្នឹងបឋម អនុវិទ្យាល័យនៅតាខ្មៅ។

ក៖ អញ្ចឹងអនុវិទ្យាល័យអ្នកមីងឈ្មោះអីគេ ហ៊ុន សែន តាខ្មៅឬក៏ម៉េច ហិ...មិនមែនទេ?

ខ៖ ពីមុនជំនាន់មុនគេហៅវិទ្យាល័យតាខ្មៅ អញ្ចឹងហ្មង។

ក៖ ហើយឥឡូវថែមឈ្មោះហ៊ុន សែនហោ?

ខ៖ អត់មានថែមទេ។

កៈ ចាសអ្នកមីងសាលារៀនអ្នកមីងនៅក្នុងខេត្តអីគេដែរ?ភូមិ ឃុំអីគេដែរ?

ខៈ ខេត្តកណ្ដាល។

កៈ ខេត្តកណ្ដាលហោ៎?

ខៈ ចាស!

កៈ ចាសអញ្ចឹងអ្នកមីងពេលអ្នកមីងកំពុងតែរៀនហ្នឹងហា៎...មានមិត្តភក្តិស្និទ្ធស្នាលអីអត់នៅក្នុងជីវិត?

ខៈ ខ្ញុំមាន មាន២ ៣នាក់ដែរចាស។

កៈ ចាសគាត់ឈ្មោះអីគេដែរ?

ខៈ តាំងពីបឋមរហូត ឈ្មោះ មាស សារិតមួយឥឡូវគេធ្វើឆ្មបនៅពេទ្យជ័យជំនះទេ អាហ្នឹងជាមិត្តភក្តិស្និទ្ធស្នាលអ្នកណាទៀតទេ ហ្ហ៎...ដល់ឡើងមកអនុវិទ្យាល័យ នីត នរីន ឥឡូវគេធ្វើម្ចាស់សណ្ឋាគារនៅកំពង់សោមតែខ្ញុំអត់ដែលបានជួបទេឮសូរតែគេថាទេ។

កៈ ម៉េចបានមិនព្រមទៅជួបគ្នាទៅមីង ធ្លាប់ស្និទ្ធស្នាល។

ខៈ អត់ដែលបាន ចុះយើងប្អែងមើលខ្ញុំ ជើងខ្ញុំនិយាយពីថាដើរទៅណាអត់រួចទេនិយាយពីខ្ញុំគេរវល់តែខឹងទេទៅណាក៏មិនរួចដែរ។

កៈ ជាប់ចៅហោ៎?

ខៈ ចៅផង ហើយណាមួយខ្ញុំអត់សូវចេះដើរផង។

កៈ ចាសហ្នឹងហើយ អញ្ចឹងអ្នកមីងចងចាំអីគេខ្លះនៅពេលអ្នកមីងនៅរៀនអញ្ចឹងហា...អ្នកមីងចងចាំអីគេខ្លះជាមួយមិត្តភក្តិរបស់អ្នកមីងលេងម៉េចដែរអញ្ចឹង?

ខៈ ហ្ហ៎...អនុស្សាវរីយ៍ច្រើនណាស់។

កៈ មីងអាចសង្ខេបខ្លះៗ?

ខៈ មិត្តភក្តិចាសជាមួយមាស សារិតហ្នឹងយើងរៀបបឋមជាមួយគ្នានៅព្រែកតាពៅ ដើរជាមួយគ្នាញុំាអីជាមួយគ្នា ទៅរៀនខ្ញុំមានកង់ទៅខ្ញុំចូលឌុបគេទៅជិះទៅទាំងអស់គ្នាទៅ

អត់កង់ខ្ញុំដើរទៅចូលហៅដើរទាំងអស់គ្នាទៅមានអីទិញញ៉ាំចែកគ្នាទៅ
ចាសស្និទ្ធស្នាលណាស់សុទ្ធតែមី ទៅមីមកអីអញ្ចឹង ស្និទ្ធស្នាលវ៉ៃទៅមកក្បាលប៉ក់ៗ ហើយបើនរីន វិញគេកូនអ្នកមាន។

កៈ ចាស!

ខៈ ចាសអាហ្នឹងនៅអនុវិទ្យាល័យ គាត់កូនអ្នកមានចេញលេងអញ្ចឹងអី គាត់ហៅខ្ញុំញ៉ាំអីៗ ហើយខ្ញុំអត់សូវមានលុយទេ យើងកូនអ្នកក្រ។

កៈ ចាស!

ខៈ គាត់ប៉ាវញ៉ាំហើយគាត់ល្អណាស់កូនហ្នឹង
ហើយចេះអីអញ្ចឹងជួយពន្យល់យើងបង្រៀនយើងថាយើងរៀនខ្សោយអញ្ចឹងគាត់ជួយណែនាំយើងឱ្យយើងយល់ចេះអញ្ចឹងអីហា។

កៈ គាត់រៀនពូកែ?

ខៈ ចាសគាត់រៀនពូកែ។

កៈ ចាសអញ្ចឹងអ្នកមីង អ្នកមីងធ្វើការ តើធ្លាប់អ្នកមីងធ្វើការស្រែចម្ការអីអត់?

ខៈ ខ្ញុំអត់ដែរសោះ។

កៈ អត់ដែលហ្មងហេ?

ខៈ ចាសដឹងតែមានបែកពីអាពតមកយើងមានគ្រួសារធ្វើមេផ្ទះរហូត។

កៈ ចាស!

ខៈ ប៉ុន្តែបើបានប៉ុន្មានទេខ្ញុំចូលធ្វើការបានប៉ុន្មានឆ្នាំដែរ។

កៈ ធ្វើការអីគេវិញអ្នកមីង?

ខៈ អឺ...ខ្ញុំដំបូងដូចឆ្នាំប៉ុន្មានទេនេះ ១៩០០កៅប៉ុន្មានទេខ្ញុំចូលនៅក្នុងអង្គការមួយគេហៅអង្គការបង្កើតច្បាប់ការងារ
ចាសចូលធ្វើការនៅអង្គការហ្នឹងខ្ញុំដើរសម្ភាសដូចហ្នែងអញ្ចឹងខ្ញុំចូលសម្ភាសតាមអ្នកមុខរបររកស៊ីតាំងពីមុខរបរស្រីខូច តាំងពីមុខរបរសំនង់ តាំងពីកម្មកររោងចក្រគ្រប់
បែកចែកគ្នាដើរចូលដើរសម្ភាស

សម្អាសបានយកឯកសារហ្នឹងមកមើលទៅតើការងារណាដែលធ្ងន់ធ្ងរជាងជាងគេ គេស្រាវជ្រាវទៅគឺថាមានតែការងាររោងចក្រទេដែលយើងចុះទៅបង្កើតសាជីបឱ្យគេ សហជីបមិនមែនពួកហ្នឹង សហជីបខ្មែរហ្នឹងសុទ្ធតែពួកខ្ញុំបង្រៀនទាំងអស់ មេខ្ញុំអាមេរិចកាំង តែឥណ្ឌាទេ ស្រីឥណ្ឌាហា...មុនដំបូងអាមេរិចកាំងដេវិត អាមេរិចកាំង ដល់ដូរមក ២ឆ្នាំដូរមកអាមេរិចកាំងស្រី បាម៉ា អាហ្នឹងឥណ្ឌាទេខ្មៅថៅហ្វាយខ្ញុំ។

ក៖ ចាស!

ខ៖ ហើយគាត់បង្រៀនយើងឱ្យចេះពីរបៀបចុះសួរ ចុះធ្វើម៉េចទំនាក់ទំនងរៀបដូចថាបង្កើតសហជីបហ្នឹងហាំ...ឱ្យខ្ញុំបង្រៀនពួកខ្ញុំហើយអញ្ចឹង ឱ្យខ្ញុំចុះតាមរោងចក្រ ចុះតាមរោងចក្រ អញ្ចឹងទៅបានទៅយើងបានយើងទំនាក់ទំនងកម្មករសួរគេ សួរអីពីនេះពីនោះ ចូលសាច់រឿងថាឱ្យយើងបង្កើតក្រុមមួយដើម្បីតវ៉ាទាមទារច្បាប់អីហ្នឹងដើម្បីកុំឱ្យថៅកែជិះជាន់ ឱ្យយើងធ្វើការថែមម៉ោង បញ្ឈប់យើងគ្មានកំហុស គ្មានអីអញ្ចឹងៗហា។

ក៖ ចាស!

ខ៖ យើងពន្យល់ប្រាប់គេថាអញ្ចឹងទៅ ពួកគេសុខចិត្តធ្វើហើយគាត់បង្កើតច្បាប់ ច្បាប់ការងារសព្វថ្ងៃហ្នឹង គាត់អ្នកបង្កើតតិចៗមកបានចេញ ១៩៩៧អីបានច្បាប់ការងារចេញ ពួកខ្ញុំអ្នកខំចុះរៀបចំ។

ក៖ ចាស!

ខ៖ អាពេលថ្ងៃ៥ ថ្ងៃ៦ហ្នឹងបានស្ទះបិទការងារអញ្ចឹងទៅពួកខ្ញុំត្រូវផ្អាកមួយរយៈពួកខ្ញុំបើកលុយផ្តាច់ពួកខ្ញុំឈប់ទាំងអស់ ពេលហ្នឹងធ្វើបានប៉ុន្មានឆ្នាំទេហើយដល់មកសារក្រោយអង្គការហ្នឹងគេត្រលប់មកវិញតែគេដូរឈ្មោះអង្គការហើយថៅហ្វាយវាអាមេរិចកាំង សុទ្ធតែប្រុសហើយបានគេហៅខ្ញុំចូលធ្វើវិញខ្ញុំចូលធ្វើតែមួយរយៈហ្នឹងទៀតទៅខ្ញុំទៅធ្វើជាអ្នកជួយជំនួយការច្បាប់ ខ្ញុំនៅក្បែរមេធាវីខ្ញុំដើរតាមគាត់រហូតហើយជួយសរសេរពាក្យបណ្តឹងអីៗកម្មករអ្នកណាគេដូចថាថៅកែបញ្ឈប់គ្មានកំហុសអញ្ចឹងអីហា...យើងជួយដាក់ពាក្យប្តឹងជួយឡើងទៅ មេធាវីខ្ញុំឡើងទៅតុលាការជួយតវ៉ានិយាយការពារកូនក្តីអីអញ្ចឹងហា....ហ្នឹងហើយខ្ញុំបានជួយ

គេរហូតអញ្ចឹងមក
ហើយដល់ពេលឥឡូវហ្នឹងវាអត់មានអាពេលហ្នឹងដូចថាប្រទេសយើងវាចង់បិទជំនួយបិទអីកាលហ្នឹងគេគម្រាមពេកហា។

ក៖ ចាស!

ខ៖ គម្រាមថាបើពួកហ្នឹងអត់ជួយឱ្យកម្មករមានប្រាក់ខែខ្ពស់អីទេ
តាំងពីប្រាក់ខែកម្មករនៅ៥០ដុល្លារ ៣០ដុល្លារ
ខ្ញុំធ្វើហា...ហើយយើងទាមទារឱ្យសុំប្រាក់ខែឱ្យខ្ពស់ឱ្យគ្រប់ថ្លៃទឹកថ្លៃភ្លើង
ថ្លៃឈ្នួលផ្ទះគ្នាហើយដល់ហើយទៅតវ៉ាយូរៗទៅពួកខ្ញុំបែកកន្លែងមួយបង្កើតអូសហ្វិសមួយសម្រាប់ខ្ញុំ គាត់មេធាវីខ្ញុំទៅហើយខ្ញុំនៅជួយគាត់រហូត ដល់ពេលយើងអស់ហ្វាន់
អស់ជំនួយហើយព្រោះបិទទៅ។

ក៖ ចាស!

ខ៖ ហើយគាត់ឱ្យខ្ញុំធ្វើការស្មគ្រ័ចិត្តខ្ញុំអត់ធ្វើទេអត់លុយផងហើយដើរមួយថ្ងៃៗ
ខ្ញុំហត់ណាស់អាធា។

ក៖ ចាស!

ខ៖ ព្រលឹមឡើងខ្ញុំទៅចូលអញ្ចឹងហើយសុំថាតែអ្នកសំអាត អ្នកអនាម័យមកម្នាក់ហ្នឹងគឺ ២
៣ថ្ងៃមកម្ដង រអ៊ូទៀតមីចោរម្រាយហ្នឹង ហើយខ្ញុំទៅខ្ញុំចេះតែទើស
ខ្ញុំបោសច្រាស់ជូតខ្លួនឯងទៅ ជូនអីខ្ញុំលាងចូលទៅ
ហើយទៅខ្ញុំវៃពាក្យបណ្ដឹងអីក្នុងបន្ទប់ហ្នឹងទៅ ហើយគាត់មកអញ្ចឹងទៅគាត់យកអាហ្នឹងទៅ
ត្រូវចេញចុះទៅជួបកម្មករ ម៉ោង៩ ១០ចេញទៅទៀត។

ក៖ ចាស!

ខ៖ រួចជូនកាលអត់បាយទៀតទល់ម៉ោង៣បានបានបាយ
ទៅដល់រោងចក្រក្រោមដល់ណាកំពង់ស្ពឺទៅដល់អីណាហ្នំ...។

ក៖ ចាស!

ខ៖ ប៉ុនកាលហ្នឹងគេមានឡានឱ្យយើងជូនយើងរហូត។

ក៖ ចាសប្រាកខែគួរសមដែរអ្នកមីងហេ?

ខ៖ ៣០០ ជាងដែរកាលហ្នឹង។

ក៖ ៣០០ជាងកាលហ្នឹងច្រើនហាំណាំ។

ខ៖ ចាសច្រើនហាណាស់៣០០ជាង ហ្នឹងហើយ។

ក៖ អ្នកមីងសប្បាយរីករាយនឹងការងារហ្នឹងដែរហេ៎?

ខ៖ ចាសខ្ញុំចូលចិត្តព្រោះយើងឈឺចាប់ហើយគេគាប់សង្កត់យើង យើងក្តៅក្រហាយហើយខ្ញុំ
ទៅជាមួយចិនខ្ញុំឈប់ហើយអាមេធាវីមួយនោះវាធ្លាប់ដឹងថាខ្ញុំធ្វើការហ្នឹងវាហៅ
វាទៅធ្វើការជាមួយចិន វាទៅធ្វើការជាមួយចិនហា...ហើយវាធ្វើមេធាវីការពារចិន
ហើយខ្ញុំធ្លាប់ហៅវាចូលស្តារកន្លែងខ្ញុំហា...ដូចថារបៀបយើងចុះបង្រៀនច្បាប់អីអញ្ចឹង
ចុះវាដឹងវាប្រលងធ្វើមេធាវី ជាប់វាចូលទៅធ្វើមេធាវីការពារក្តីឱ្យចិន ឱ្យសាន់តិចនេះ
ហើយវាឃើញខ្ញុំនៅទំនេរអញ្ចឹងវាគេសួរវាហៅខ្ញុំទៅ ចុះកម្សត់កម្រជាមួយវាដែរហ្នឹង
ជិះអាសាន់យាន់មួយឌុបគ្នាកាត់ព្រៃកាត់ផ្សែងចូលទៅរោងចក្រស្វាត់ៗមិនមែនបង្កើតដូចឥឡូ
វផ្ទះរីកចម្រើនទេ ពេលហ្នឹងស្វាត់ឈឹងទៅណាស់
ហើយបើវាហៅខ្ញុំទៅជួបជាមួយចិនសម្កាសទៅ
អាចិនវាក្រវីក្បាលវាអត់យកខ្ញុំទេដាក់ស៊ីវីខ្ញុំទៅ
រួចខ្ញុំថាខ្ញុំខ្ជិលណាស់ខ្ញុំមិនចង់ឱ្យអាចិនជិះជាន់ខ្មែរពេកទេ។

ក៖ ចាស!

ខ៖ ហើយវា វាអញ្ចឹងវាទិញឡានមែកស៊ីដេសឡើងខ្មៅព្រីចជិះខ្ញុំថាហ្ហ៎...ហើយទៅ
ទៅណោះហ្អែងដឹងទេរោងចក្រសាត់ត្បូវី ហ្អែងធ្លាប់ឮទេ?ដំបូងបង្អស់ពួកខ្ញុំចូលទៅ?

ក៖ សាត់ត្បូវី?

ខ៖ ចាសរោងចក្រសាត់ត្បូវី ហ្គោលវែមហា។

ក៖ ចាស!

ខ៖ ទៅតែ២នាក់មេធាវីទេ ជិះទៅហ្អែងដឹងទេ
ភូមិឃុំមេឃុំហា...ចាប់ខ្ញុំ២នាក់មេធាវីមកហៅមកយើងបញ្ចុះបញ្ចូលកម្មករតាម
ប៉ុន្តែពេលគេស៊ីបាយយើងចូលទៅដល់ហា...ពួកហ្នឹងលើកចានរត់អស់រលីង
ឃើញយើងខ្លាចហ្មងព្រោះអាមេការវាហ្នឹងកាចណាស់

អាហ្នឹងកម្មករខ្លាចវាហ្មងហើយយើងចង់ចុះទៅបង្កើតសហាជីបអីវាប្រឆាំងជាមួយវាតវ៉ាជាមួយ វាអត់បានទេ ហើយកម្មករឃើញយើងទៅវានាំគ្នារត់អស់ហើយ ហើយចេះតែទៅ ទៅៗទម្រាំបានសឹងតែចង់ងាប់ចង់រស់គេចាប់ហៅចូលប៉ុស្តិ៍អី២នាក់ អញ្ចឹងមេធាវីគាត់ជជែកគាត់និយាយពីច្បាប់ទាំងអស់។

ក៖ ចាស!

ខ៖ ចាស!

ក៖ រឿងអីចាប់បាន?

ខ៖ ចាសរឿងអីចាប់បាន ហើយដល់ទៅពួកហ្នឹងកម្មករចេះតែគេចៗពីយើងតែមានខ្លះគេតស៊ូដែរ។

ក៖ ចាស!

ខ៖ គេប្រឹងប្រែងដើម្បីសិទ្ធសេរីភាពរបស់គេដែរ។

ក៖ ចាស!

ខ៖ ឥឡូវរោងចក្រហ្នឹងដោយសារពួកខ្ញុំប្រឹងណាស់ បានបានធូរទល់សព្វថ្ងៃកុំអីអោនក្បាល អញ្ចឹងហ៎...ឃើញអាមេការហ្នឹងមកដូចស្តេចជំនាន់ដើមអញ្ចឹង។

ក៖ ចាសអញ្ចឹងពិបាកអ្នកមីងណោះ?

ខ៖ ចាស។

ក៖ ហ្នឹងហើយ។អញ្ចឹងអ្នកមីងតើអើដូចជាជីវិតអ្នកមីងពីក្មេងមកដល់ឥឡូវមានការផ្លាស់ប្តូរអីខ្លះហើយ?

ខ៖ និយាយពីការផ្លាស់ប្តូរវា...?

ក៖ ពីក្មេងម៉េចហើយមកដល់ឥឡូវដូចជាការធំធាត់មកវាម៉េចដែរ?

ខ៖ ធំធាត់ដូចថាជីវភាពអីអញ្ចឹងហោ៎?

ក៖ ចាសការរស់នៅសប្បាយចិត្តម៉េចដែរអញ្ចឹងហា៎?

ខ៖ ចាសកាលពីជំនាន់មុខខ្ញុំដូចថាខ្ញុំរស់នៅជាមួយឪពុកម្ដាយខ្ញុំនៅលីវដូចថាជីវភាពយើងតាំងពីតូចមកថាជីវភាពវាមិនសម្បូរបែបក៏វាមិនអត់ដាច់ពោះដែរគ្រាន់តែថាវាអាចបានសមរម្យជាមួយគេជាមួយឯង
ចាសដូចថាការរស់នៅជាមួយគាត់ខ្ញុំដូចវាអត់សូវសម្បូរបែបទេគឺថាខោអាវស្លៀកពាក់ខ្ញុំមិនដែលមានល្អអីហ្នឹងគេទេ ហើយគាត់ក៏មិនដែលទិញឱ្យខ្ញុំមដែរគឺថាបងប្អូនខ្ញុំរស់នៅពេល...ពេលវ៉ាកងឈប់ប៉ុន្មាន៣ខែចែកផ្លូវគ្នាដើម្បីរកលុយខ្លួនឯងដើម្បីទិញសៀវភៅខោអាវស្លៀកពាក់ទៅរៀនអញ្ចឹង។

ក៖ រកម៉េចទៅមីង?

ខ៖ អញ្ចេក...ខ្ញុំអញ្ចឹងដូចថាអ្នកមានផ្ទះធំដង្ហៅប៉ិចនេះគេហៅខ្ញុំឱ្យទៅបង្រៀនខ្មែរកូនគេហ្នឹងហើយរួចហើយទៅគេឱ្យខ្ញុំ៣០រៀលដែរ ៣ខែហ្នឹងហើយខ្ញុំអាចទិញសៀវភៅ
ទិញខោអាវស្លៀកបាន បងប្រុសខ្ញុំចែកជើងគ្នាខ្លះទៅរែកអុស
រែកអុសគេដាក់ឡដុះឡរែកឡើង ទៅរៀប អុសឱ្យគេអញ្ចឹងទៅ
ហើយបងប្រុសខ្ញុំខ្លះធ្វើឥដ្ឋការ៉ូ
ជួយរុញឥដ្ឋការ៉ូគេហ្នឹងបានលុយបងប្រុសខ្លះទៅនៅជាមួយបងជីដូនមួយអញ្ចឹងទៅរែកទឹករែកអីពុះអុសឱ្យគេទៅគេឱ្យ បានពេលចូលកងវិញគេឱ្យលុយអញ្ចឹងយើងទិញស្លៀកពាក់ទៅចាសជួយឪពុកព្រោះអីគាត់ជួយយើងអត់បានព្រោះយើងធំៗធាត់ហើយ។

ក៖ ចាស!

ខ៖ ប្រាក់ខែអាត្រែតតិចហ្នឹង។

ក៖ ចាស!

ខ៖ ចាសហើយដល់ពេលខ្ញុំចាប់មានគ្រួសារជំនាន់ប៉ុល
ពតមកគឺថាក្រុមគ្រួសាខ្ញុំប្ដីប្រពន្ធខ្ញុំល្អគ្នាណាស់
អត់ដែលប្រកែកអីដូចថាអត់ដែលឈ្លោះទាស់ទែងអីគេទេសុខសាន្តគ្នារហូត
រហូតមកដល់សម័យបច្ចុប្បន្នប្ដីខ្ញុំគាត់ធ្វើការនៅក្នុងរោងចក្របារីរំដោះទេមិនមែនបច្ចុប្បន្នទេអតីតកាលដែរឥឡូវគាត់រ៉ឺរត្រែតហើយ ចាសគាត់បានប្រាក់ខែកាលហ្នឹងដំបូងបាន៣០រៀលហើយកូន៣ចិញ្ចឹម ចាសហើយគាត់ឆ្លៀតរត់កង់ឌុបទៀត
ចាសពេលចេញព្រលឹមឡើងអញ្ចឹងគាត់ចេញពីព្រឹកម៉ោង៦អញ្ចឹងទៅឌុបម៉ូយកង់ឌុបអញ្ចឹងទៅបានលុយត្រលប់មកវិញអញ្ចឹងទៅ ទៅគាត់ដោះខោអាវចូលផ្ទះគេទៅ គាត់ចូលធ្វើការទៅ

ហើយចេញមកវិញបានគាត់មកផ្ទះ ហើយបើល្ងាចអញ្ចឹង
ពេលល្ងាចអញ្ចឹងគាត់រត់កង់ឌុបអញ្ចឹងទៅ
ហើយចូលអូរឬស្សីទិញត្រីចៀន២អីជិះមកផ្ទះហើយ ថ្ងៃខ្លះបែកកង់
កង់ពិបាករេស៊ីប៉េសំបកវានោះដេរ មកដល់ផ្ទះខ្ញុំចាំយូរអើយយូរ
ទៅណាបាត់យប់ហ្មុំ...ដល់មកវិញបែកកង់បណ្ដើរតាំងពីភ្នំពេញដល់ផ្ទះយកមកអញ្ចឹងហូបបាយហូបអីហើយអញ្ចឹងអង្គុយដេរសំបកកង់ហ្នឹង រត់ទៀតជិះទៅធ្វើការទៀត
ណាស់ជីវិតខ្ញុំតស៊ូប្ដីប្រពន្ធខ្ញុំហា។

កៈ សម័យហ្នឹងអត់ទាន់មានម៉ូតូមានអីណាមែនទេ?

ខៈ ចាសអត់ទាន់ទេចាស។

កៈ ចាសអញ្ចឹងអ្នកមីងសម្រាប់ម្ហូបអ្នកមីងចូលចិត្តពិសារម្ហូបអីជាងគេ?

ខៈ ខ្ញុំវាឥឡូវចាស់ទៀតខ្ញុំវាមិនដឹងចង់អី។

កៈ អញ្ចឹងតាំងពីក្មេងមកម្ហូបមីងចូលចិត្តជាងគេអញ្ចឹងហាំ?

ខៈ ពីក្មេងខ្ញុំចូលចិត្តម្ហូបខ្មែរសម្លរម្ជូរយួនជាងគេ។

កៈ ចាស!

ខៈ ប៉ុន្តែដល់ឥឡូវចាស់ទៅលែងចង់អីអស់ហើយ។

កៈ ចាសអ្នកមីងមានចេះធ្វើម្ហូបអីទាំងអស់ហ្នឹងអត់?

ខៈ អត់ចេះគ្រាន់តែថាវាមិនដាក់មានទឹកដៃអីឆ្ងាញ់ដូចប្អូនខ្ញុំទេ គេពូកែខ្ញុំអត់ទេ
អត់ចេះធ្វើអីច្រើនទេគ្រាន់ថាហូបៗសាមញ្ញហ្នឹងបាន។

កៈ អញ្ចឹងម្ហូបទាំងអស់ហ្នឹងអ្នកណាគេបង្រៀនវិញ ហីចេះធ្វើដោយខ្លួនឯង?

ខៈ ចេះពីម្ដាយខ្ញុំហ្នឹងគាត់បង្រៀនធ្វើ គាត់ស្លរយើងមើលអញ្ចឹងទៅគាត់ប្រាប់ធ្វើនេះធ្វើនោះ
ដាក់នេះដាក់នោះអញ្ចឹងទៅចេះពីគាត់មកចាស ។

កៈ ចាសអញ្ចឹងអ្នកមីងអ្នកមីងចូលចិត្តស្ដាប់បទចម្រៀងអីអត់?

ខៈ បទចម្រៀងខ្ញុំចូលចិត្ត ឥឡូវនេះ សម័យនេះហោ៎?

កៈ តាំងពីសម័យណាក៏បានដែរ។

ខៈ ចូលចិត្តបទសង់ទីម៉ង់ ដូចថារស់ សេរីសុទ្ធាអញ្ចឹងហា។

កៈ ចាស!

ខៈ ចូលចិត្តបណ្តែតអារម្មណ៍ តាមអាពេលផ្សេងៗ ចូលចិត្តបទជំនាន់ខ្ញុំនៅរៀនបឋម រាត្រីសេកុង អ្នកគ្រូខ្ញុំចូលចិត្តណាស់ ពេលណាថ្ងៃសៅរ៍ឡើងគាត់ហៅខ្ញុំឡើងច្រៀង ហើយច្រៀងបទអីខុសពីហ្នឹងគាត់អត់ព្រមទេ គាត់ឱ្យច្រៀងតែបទហ្នឹង។

កៈ ពិរោះមីងហេ៎?

ខៈ គាត់ថាពិរោះ ហើយមិនពិរោះអីគាត់ទេចេះតែច្រៀងៗហ្នឹង។

កៈ អ្នកចម្រៀងមួយណាអ្នកមីងចូលចិត្តនេះជាងគេ ចូលចិត្តស្តាប់គាត់ជាងគេ ស្រលាញ់គាត់ជាងគេហា៎?

ខៈ ហ្នឹងចម្រៀងណា សម័យណា?

កៈ សម័យណាក៏បានដែរដែលចូលចិត្ត ទោះសម័យមុន សម័យឥឡូវអញ្ចឹងទៅណាស់។

ខៈ បើខ្ញុំ ខ្ញុំចូលចិត្តហួយ មាស។

កៈ ហួយ មាស?

ខៈ សម្លេងគាត់ស្រួយតូច គាត់និយាយល្ងោននិយាយពិរោះ ខ្ញុំចូលចិត្តគាត់ច្រៀង។

កៈ ជាងគេហើយហ្នឹងមីងណោះ?

ខៈ ហ្នឹងហើយ!

កៈ
អញ្ចឹងអ្នកមីងតើនៅក្នុងផ្ទះក្រុមគ្រួសារអ្នកមីងមានអ្នកណាគេចេះលេងភ្លេងចេះលេងអីអត់?

ខៈ ដូចជាអត់មានអ្នកណាចេះទេ អត់ចេះទេ។

កៈ ហ្គីតា ព្យាណូអី?

ខៈ អត់ទេ  អត់ចេះសោះ ចាសអត់។

កៈ
ចាសអញ្ចឹងអ្នកមីងតើអ្នកមីងនៅផ្ទះហា...ផ្ទះអ្នកមីងនៅតាំងពីក្មេងផ្ទះសណ្ឋានរបៀបយ៉ាងម៉េចទៅមីងពីក្មេងមក?

ខៈ ពីតូចមក?

កៈ ចាស!

ខៈ ជំនាន់ខ្ញុំនៅតូចខ្ញុំដឹងក្ដីស្រពេចស្រពិលផ្ទះខ្ញុំផ្ទះឈើ ជំនាន់តាំងពីជីដូនម្ដាយប៉ាខ្ញុំមកហា។

កៈ ចាស!

ខៈ ហើយគាត់ផ្ទះឈើសសរមូលហើយវាមាន៣ខ្នង
ហើយជំនាន់ហ្នឹងផ្ទះជំនាន់បុរាណខ្មែរពីដើមហា...ហើយដល់ភ្លើងឆេះផ្ទះ ភ្លើងឆេះអស់
ចាសភ្លើងឆេះសឹងតែអស់ជីវិតប្អូនខ្ញុំមួយទៀតហ្ន៎...ភ្លើងឆេះអស់ទៅពួកយើងធ្លាក់ខ្លួនទៅបាន
ថៅកែរោងចក្រនេះគេអាណិតគេឱ្យយើងជ្រកផ្ទះគេនៅខាងណោះ
ផ្ទះគេច្រើននោះគេឱ្យផ្ទះយើងមួយប៉ុន្តែកាត់មួយចំហៀងទេគេឱ្យយើងមួយចំហៀងហើយប៉ុណ្ណឹងដែរកាត់ខ្ញុំនៅមួយគ្រួសារមួយចំហៀងហើយគេខណ្ឌអញ្ចឹងទៅ
ឱ្យយើងនៅបណ្ដោះអាសន្នបានយើងជ្រកផ្ទះគេហើយខោអាវអីគេឱ្យយើងស្លៀកពាក់
ហើយយើងអស់រលីង ឆេះអស់រលីងមានយកអីបាន។

កៈ អូយ...អាភ្លើងឆេះផ្ទះពិបាកអ្នកមីងណោះ?

ខៈ ចាសខ្ញុំគ្រាន់អត់២ ៣ដំណាក់ហា...អញ្ចឹងហា។

កៈ សុទ្ធតែអាធំៗហ្មងមីងណោះ?

ខៈ ហ្នឹងហើយសុទ្ធតែអាធំ មកជំនាន់អាពតក៏អស់ទៀត ហ្ន៎...អាលីង។

កៈ អញ្ចឹងអ្នកមីង អឺ...អ្នកមីងធ្លាប់ត្បាញកន្ទេល កន្ត្រកអីអត់?

ខៈ ហ្ន៎...ជំនាន់អាពតវាបង្រៀនត្បាញសារុង។

កៈ ម៉េចវិញទៅមីង?

ខៈ អត់ចេះដែរ ប៉ុន្តែឥឡូវភ្លេចហើយ បង្រៀងចុះពេលយើងឈប់ហ្ន៎...ឈប់សម្រាកយប់
អញ្ចឹងវាឱ្យយើងវាអត់ឱ្យយើងទំនេរអញ្ចឹង យើងត្បាញសារុង

ត្បាញកន្ទេលទៅខ្ញុំចេះត្បាញការុងប៉ុន្តែខ្ញុំភ្លេចបាត់ហើយអញ្ចេះៗ
ចេះតែខំធ្វើលើកទុកលើកដាក់នឹងគេហ្នឹង។

កៈ ចាសហ្នឹងហើយ អញ្ចឹងអ្នកមីងសូមរៀបរាប់ពីជីវិតរបស់អ្នកមីងហាំ...ពេលជំនាន់លន់ នល់មុនអ្នកមីងមានចាំពេលជំនាន់លន់ នល់ទេ?

ខៈ ចាសជីវិតពេលខ្ញុំនៅជំនាន់ លន់ នល់ ខ្ញុំនៅលីវទេ។

កៈ ម៉េចទៅអ្នកមីង?

ខៈ ជីវិតជំនាន់ហ្នឹងវាសប្បាយព្រោះយើងកំពុងវ័យកំពុងសប្បាយ វ័យ១៥ ១៦ ១៨ឆ្នាំចាស ១៨ ១៩ហ្នឹងកំពុងវ័យសប្បាយ។

កៈ ចាស!

ខៈ ហ្ហ៎...កាលហ្នឹងខោប៉ាត់ អាវសង់ត្រេរ ជិះប៉េសេដើរលេង អីទៅណាសប្បាយណាស់ទៅសៀតព្រីណា ទៅរាំជាមួយមិត្តភក្តិអីណាអូយ...ចេះតែទៅជាមួយគេជាមួយឯងហើយខ្ញុំ។

កៈ តែពេលហ្នឹងដូចអត់មានទម្លាក់គ្រាប់ទម្លាក់អីបានអ្នកមីងដើរលេងបាន?

ខៈ ហេ...អាហ្នឹងនៅក្រុង អាមួយខេត្ត អាមួយខេត្តបានគេវេទនាតែខ្ញុំនៅក្រុងវាកំពុងសប្បាយហើយវាកំពុងយុវវ័យកំពុងពេញសប្បាយ។

កៈ ចាស!

ខៈ
ចាសប៉ុន្តែយើងក៏មិនបានទៅភ្លើតភ្លើនអីគេដែរគ្រាន់តែថាយើងឪពុកម្តាយយើងគាត់ចេះតែហាមប្រាមមិនបណ្តោយឱ្យទេណាស់ ឱ្យទៅមានមិត្តភក្តិអីអញ្ចឹងទៅ
ទៅញ៉ាំអីរាំលេងជាមួយគ្នាអញ្ចឹងទៅ
អាហ្នឹងមានពេលខ្លះដូចបងខ្ញុំអីនាំមិត្តភក្តិមកផ្ទះមកញ៉ាំអីអញ្ចឹងទៅ
កាលបានជំនាន់អាពតវ៉ៃចូលហ្នឹងធ្វើម្ហូបអីញ៉ាំអញ្ចឹងមិត្តភក្តិបងប្រុសខ្ញុំហ្នឹងថានាំគ្នាមកញ៉ាំហ្នឹង ដល់កុងក្តាំងហ្នឹង ផ្លោងកុងក្តាំងហ្នឹង បែកគ្នានាំគ្នារត់អស់អាលីងហ្នឹង
ចាសចោលឆ្នាំងចោលសម្លរពេញផ្ទះតែទាំងអស់ហ្នឹង។

កៈ តែមានផ្លោងមកដល់ភ្នំពេញអត់មីង?

ខ៖ ពេលចូលមកផ្លោងចូល តែពេលអាវានៅជាយៗវាអត់អីទេណាស់ ដល់ពេលវាចូលត្រឹមថ្ងៃទី១៧មេសាហ្នឹងដល់ភ្នំពេញហ្មង។

ក៖ នេះលន់ នល់ហាំ?

ខ៖ ចាសហ្ហ៎...ជំនាន់លន់ នល់។

ក៖ ចាស!

ខ៖ មិនមែនជំនាន់ប៉ុល ពតចូលទេហោ?

ក៖ អឺ...លន់ នល់ មុនសិន។

ខ៖ លន់ នល់មុន ដូចខ្ញុំថាវាតែខាងក្រៅទេវ៉ៃគ្នា អាប៉េសអាប៉េះនៅជាយៗខេត្តនៅជាយៗអញ្ចឹងហា។

ក៖ ចាស!

ខ៖ ចាសហើយមានយូរៗផ្លោងក្រាំងៗចូលមកជិតៗហ្នឹងដែរ ។

ក៖ ហ្ហ៎...!

ខ៖ ឃើញហោពួកខ្ញុំ បងៗខ្ញុំវតែថាខ្ញុំបងរីណៃហូបបាយពីថ្ងៃៗខ្លាចគ្រាប់ផ្លោង ធ្លាប់ទៅ។

ក៖ ចាស!

ខ៖ តែម៉ោង៣ អីបាយឆ្អិនអស់ហើយ ម៉ែខ្ញុំដាំបាយឆ្អិនអស់ហើយ។

ក៖ ហើយនាំគ្នាចូលផ្ទះអញ្ចឹងទៅ?

ខ៖ ចាសញ៉ាំបាយអីហើយអញ្ចឹងនាំគ្នាគ្រែអញ្ចឹងទៅនាំគ្នាចូលគេងក្រោមគ្រែទៅ ដាក់ខ្នើយបាំងៗខ្លាចវាផ្លោង ខ្លាចវាជះហា...គេងអញ្ចឹងទៅផ្ទះយើងទៀមដីហើយជូនណាវាគេចក្រាំងៗហ្នឹងភ័យដែរហ្នឹង។

ក៖ ចាសអញ្ចឹងអ្នកមីងកាលរស់នៅក្នុងជំនាន់លន់ នល់ដូចជាគ្រាប់ផ្លោងហ្នឹងវាប៉ុន្មានឆ្នាំដែរ?

ខ៖ លន់ នល់ ដូចជំនាន់លន់ នល់ដូចប៉ុន្មានដូចមួយឆាបមិនដឹងប៉ុន្មានឆ្នាំទេ។

ក៖ ខ្ញុំដឹងថា១៩៧០រហូតដល់៧៥ប៉ុន្តែវាធ្លាក់គ្រាប់រាល់ថ្ងៃឬក៏ម៉េច?

ខ៖ គ្រាប់ គ្រាប់ផ្លោង ផ្លោងរាល់តែថ្ងៃហ្នឹងវ៉ៃគ្នាខាងយើងស្រោចស្រង់ជាតិហើយខាងយេកកុង ហ្នឹង យេកកុងហ្នឹងវ៉ៃគ្នារាល់តែថ្ងៃហ្នឹង។

ក៖ ចាស!

ខ៖ ទាហានយើងទាហានយួនហ្នឹងវ៉ៃគ្នារាល់តែថ្ងៃមិនដឹងយួនមិនដឹងខ្មែរវ៉ៃគ្នាហ្នឹង ជំនាន់ហ្នឹងយើងវាមិនដឹងដែរ។

ក៖ ចាស!

ខ៖ ហើយអាហ្នឹងដូចសប្បាយផងហើយភ័យផង លាយគ្នាជំនាន់ហ្នឹងហា...ដូចថាវាកំពុងសេរីស្រុកហា...ជំនាន់លន់ នល់ស្រុកគេសេរីវាអត់ងាយវាសាធារណៈរដ្ឋវាមែន។

ក៖ វាមិនមែនលទ្ធិប្រជាធិបតេយ្យ?

ខ៖ វាមិនមែនលទ្ធិប្រជាធិបតេយ្យទេ។

ក៖ ហ្នឹងហើយ។គាត់របបគ្រប់គ្រងគឺសាធារណៈរដ្ឋ។

ខ៖ ចាស!

ក៖ ហើយអញ្ចឹងអ្នកមីងពេលអឺ...ដូចជាពេលក្នុងជំនាន់អឺ...សម័យលន់ នល់ហ្នឹងតើការគ្រប់គ្រងរបស់លន់ នល់ហ្នឹងវាយ៉ាងម៉េចដែរទៅប្រជាជនអីមានការងារធ្វើឬក៏រកស៊ីអីស្រួលប្រួល?

ខ៖ ខ្ញុំថា ខ្ញុំកាលហ្នឹងរកខ្ញុំនៅតូចដែរដូចថាវាអត់ទាន់ក្តាប់អាពីក្នុងសង្គមហ្នឹងឱ្យបានជ្រៅហាខ្ញុំវានៅធំៗ ហ្នុ៎...១៧ ១៨វាអត់ទាន់ដឹងអីដល់ឈប់រៀនហា...បានដឹងថាសប្បាយ សម្រាប់យុវ វ័យសប្បាយតែសម្រាប់មន្ត្រីរាជការខ្ញុំអត់ដឹងតែរឿងលុយវាពុករលួយខ្លាំងហា...លុយវាដូចប ងខ្ញុំអីវាស៊ីខ្មោចទាហានអីទាំងបាវៗចុះអាខ្មោចងាប់នោះ ងាប់ទៅលុយប្រាក់ខែវា យើងបើកយកបើកយកមក ស៊ីៗលុយខ្មោចហា...អាហ្នឹងគេហៅស៊ីលុយខ្មោចហា...វាចឹង។

ក៖ ចាសពេលហ្នឹងមីងមានហា...មីងហ៎ោ?

ខ៖ មិនមានប៉ុន្មានទេគ្រាន់តែថាម៉ារស់ស្រួលអញ្ចឹងទៅ
តែលុយវាចាយវាថោកហ៊ី...បានមកហ្អែងមើល៥០០បានសាច់ជ្រូកប៉ុណ្ណេះហ្នឹង
ហ្អែងមើលគិតមើលជំនាន់រូបគោហ្នឹង។

ក៖ ហើយគេមាននេះទេមីង ចាប់ទាហានច្រើនទេ?

ខ៖
ចាប់ហ្ន៎...ជំនាន់ហ្នឹងទាហាននិយាយពីរត់គ្នាចង់ងាប់ចង់រស់ហើយហា...ទាំងបងគេបងឯងអី
ហើយរុញចូលទាហានចាប់ហ្អែងមកទាញឡើងឡាន ទាញឡើងឡានរត់ចូលសេអ៊ីទាំងអស់។

ក៖ សេអ៊ីហ្នឹងម៉េចទៅមីង?

ខ៖ សេអ៊ីហ្នឹងកន្លែងហ្វឹកហ្វឺនទ័ពហា...សេអ៊ីហ្នឹងទៅបង្ហាត់ទ័ពហា...វាហ្អែងដែលឃើញសេអ៊ី?

ក៖ ហ្នឹងហើយ កន្លែងហ្វឹកហ្វឺនកងទព័។

ខ៖ កន្លែងហ្វឹកហ្វឺនកងទ័ព។

ក៖ តែពេលហ្នឹងក៏វាមិនដល់ជំនាន់ប៉ុល ពតដែរមីងណោះ គ្រាន់តែ...។

ខ៖ ចាស!

ក៖ គ្រាន់តែមានការវ៉ៃគ្នា។

ខ៖ ច្របូលច្របល់វ៉ៃគ្នាយើងដូចថាសប្បាយផងភ័យផង
អ្នកនៅខេត្តអញ្ចឹងជាយៗភ័នឹងគ្រាប់ផ្លោងនិងខ្មាំងចូលហើយអ្នកនៅក្រុងអញ្ចឹងសប្បាយទៅ
ណាស់។

ក៖ ចាស!

ខ៖ ភ្លើងពណ៌សប្បាយទៅអ្នកណាគេមានលុយគេសប្បាយទៅ អញ្ចឹងបានថាវាជំនាន់លន់
នល់សប្បាយផងភ័យផងអី ផងចម្រុះគ្នាហ្នឹង។

ក៖ ចាសតែគ្រាន់តែដឹងថាវាផ្លោងតែខេត្តប៉ុន្តែនៅក្រុងសុវត្ថិភាពជាង។

ខ៖ ក្រុងសុវត្ថិភាពជាងអញ្ចឹងបានម្នាក់ៗរត់ចូលទៅតែភ្នំពេញទេ។

ក៖ ហ្ន៎...!

ខ៖ អ្នកខេត្តរត់មកភ្នំពេញអត់ស្ងាត់អស់ហើយចាស។

ក៖ ហ៊ឺ...វាច្បាំងគ្នាតែទាហានៗណោះទេ។

ខ៖ នេះហាំ...ប្រជាជនជម្លៀសខ្លួនឡើងចូលក្រុងអស់មូលនៅភ្នំពេញហ្នឹង។

ក៖ ចាសមនុស្សអាញ៉ុកអាញ៉ែច្រើនណាស់មីងណេះ?

ខ៖ ចាសអាញ៉ែអាញ៉ុកពេញ តែអាញ៉ែអាញ៉ុកក៏អត់ចង្អៀតដូចនៅភ្នំពេញដែរ មែនតើ។

ក៖ ឥឡូវចង្អៀតជាង?

ខ៖ ចង្អៀតជាងហ្ន៎...សូម្បីតែឡាន
ពីមុនសូម្បីតែឡានម៉ូតូអីយើងឆ្លងថ្នល់ស្រួលឥឡូវពិបាកឆ្លងណាស់។

ក៖ ឆ្លងមិនស្រួលពិបាកទៀត។ចាសអញ្ចឹងអ្នកមីងរៀបរាប់ពីជំនាន់ប៉ុល
ពតវិញម្តងថាដោយសារអ្នកមីងពេលជំនាន់ហ្នឹងដឹងក្តីអាយុឡើងចង់២០មីងណោះ?

ខ៖ ចាស!

ក៖ ចាសចុះអ្នកមីងថ្ងៃដំបូងនៃការកើតជំនាន់ប៉ុល
ពតហ្នឹងវាយ៉ាងម៉េចដែរអ្នកមីងអាចរៀបរាប់តាំងពីជីវិតអ្នកមីងពេលចាប់ផ្តើមប៉ុល
ពតថ្ងៃដំបូងរហូតដល់ថ្ងៃដាច់អញ្ចឹងហាំ?

ខ៖ វារយៈពេលប៉ុន្មាន ៣ឆ្នាំ៨ខែប៉ុន្មាន?

ក៖ ២០ថ្ងៃហ្នឹងហោ?

ខ៖ ២០ថ្ងៃ ចាសខ្ញុំពេលជម្លៀសចេញក្រុមគ្រួសារខ្ញុំទៅតែខ្លួនទៀតអត់មានស្អីទៅទេព្រោះ
យើងភ័យនឹងគ្រាប់ផ្លោងផងហើយដូចថារត់ទៅពួនផ្ទះនេះ ព្រោះអីផ្ទះគេមានរូងអាក្រោម
អញ្ចេះ ខាងក្រោមគេហៅអាក្រោមដី។

ក៖ ត្រង់សេហ៎?

ខ៖ ចាសផ្ទះក្រោមដី អត់ទេជីកអញ្ចឹងកាលហ្នឹងគេរកស៊ីស្ករហ្ន៎...គេដាក់ស្ករស្តុកក្រោមហ្នឹង
អញ្ចឹងហាំ...ក្រោមអញ្ចឹងថ្មីមវាប្រហែលប៉ុណ្ណឹង
រួចចូលទៅពួនហ្នឹងមួយភូមិហ្នឹងម៉ុហ្នឹងរត់ទៅពួនហ្នឹងទាំងអស់ហើយទៅមានខោអាវអីនៅនឹង
ជាប់ខ្លួនស្អី។

កៈ ទៅពួនពេលជំនាន់ប៉ុល ពតហ្នឹង?

ខៈ ពេលវៃចូល?

កៈ ចាស!

ខៈ និយាយពីពេលវៃចូលដល់អញ្ចឹងទៅយើងចេះតែពួនចុះគ្រាប់
ចេះតែក្តុងៗមកមិនដឹងធ្លាក់នៅឯណាខ្លះហើយដល់ពេលអញ្ចឹងទៅដល់ពេលពួកហ្នឹងវាឡើង
មក សាច់ទ័ពគេឡើងមកដេញយើងចេញក្រៅផ្ទះអស់អត់ឱ្យយើងចូលផ្ទះទេ
បើយើងចំតែខ្មែរទ័ពពួកខ្ញុំ
ពួកខ្ញុំអត់បានចូលផ្ទះដោយសារចំខ្មែរទ័ពវាឡើងមកវាអត់ឱ្យយើងចូលផ្ទះយកឥវ៉ាន់
ចាសហើយដល់ចេញទៅជម្លៀសឱ្យយើងដើរទៅរហូត ខ្ញុំស្លៀកសារុងកញ្ចាស់រហែកមួយ
នឹកឃើញថាអញ្ចេក ហ៊ឺ...ម៉ាអង្គុយនៅនឹងដីពួនអីអញ្ចឹងស្លៀកអីស្អាត
ស្លៀកតែសារុងរហែកទៅកុំឱ្យវាប្រលាក់នៃ...ទៅសារុងរហែកមួយស្លៀកទៅ។

កៈ ហើយលែងបានមកផ្ទះរហូត?

ខៈ អត់មានបានចូលផ្ទះតែឆ្នាំងក៏មិនបាន អំបែងមួយមិនបានផង។

កៈ អូយ...យ៉ាប់ងាប់ហើយមីង?

ខៈ ចាសហើយរួចទៅ ទៅអញ្ចឹងបានទៅឱ្យយើងសម្រាកតាមវត្តមួយៗអញ្ចឹងឱ្យចែកអង្ករ
ដាក់ពោត ចែកអីឱ្យយើងដាំញុំាហាំ...ហើយទៅរកសុំឆ្នាំងគេអីគេឆ្នាំងកញ្ចាស់ៗយកមកឯ
ណាបងប្អូនគេយកមកគេច្រើនអញ្ចឹងទៅយើងសុំគេមួយអញ្ចឹងទៅគេឱ្យយកមកដាំបាយហូប
ទៅ
តែម្តាយធំខ្ញុំហ្នឹងគាត់រ៉ាប់រងទាំងអស់ខ្ញុំអត់ដឹងហើយខ្ញុំដឹងអីបើនៅក្មេងអឺ...ដឹងអីហើយជម្លៀ
សទៅនៅដល់កោះធំហើយ ហើយរបបគេឱ្យញុំាតែពោតទេ
ពោតក្រហមកិនគេចែករបបពោតហ្នឹងឱ្យយើងប៉ុន្មានម្នាក់ ប៉ុន្មានគីឡូក្នុងមួយនាក់អញ្ចឹងទៅ
ហើយយើងកិនញុំាខ្លួនឯងហើយយើងកិនទល់យប់
មួយយប់ទល់ភ្លឺអីហ្ន៎...បណ្តាក់គ្នាកិនអាត្បាល់ដៃហ្ន៎...ចាសកិន
ហើយយកមកអុំហើយយាយហ្នឹងគាត់ធ្វើទាំងអស់ហើយខ្ញុំអត់ចេះធ្វើទេ។

កៈ ចាស!

ខៈ ចុះយើងកាលហ្នឹងមិនស្គាល់ដើមស្រូវម៉េចផងហ្នឹង។

កៈ នៅតែក្រុងរហូត?

ខៈ ហ្នឹងហើយ។

កៈ ពេលកំពុងសប្បាយពេលកំពុងយុវវ័យមីងហ្ន៎...?

ខៈ ចាសកំពុងវ័យសប្បាយហើយ
ហ៊ីទៅដល់ណោះទៅគេ...ហើយយើងព្រលឹមឡើងទៅធ្វើការគេឱ្យយើងទៅធ្វើការទៅ
ទៅច្រូតទៅធ្វើស្មៅពោតទៅដាំសណ្តែកទៅដាំអីអញ្ចឹងហា។

កៈ ចាស!

ខៈ ចាសគេឱ្យយើងទៅធ្វើការរហូតប៉ុន្តែចែកជាក្រុមយុវជន យុវនារីអីអញ្ចឹង
វាចែកគ្នាអញ្ចឹងហា។

កៈ ចាស!

ខៈ លើកភ្លឺ ជីកប្រឡាយ ធ្វើសព្វគ្រប់ហា។

កៈ អញ្ចឹងអ្នកមីងពេលចាប់ផ្តើមដំបូងវាដូចជាមានអ្នកណាគេដឹងពីគោលដៅរបស់ប៉ុល ពតថា
ឱ្យទៅណានៅ?

ខៈ អត់មានគោលដៅទេ គេចេះតែដេញយើងឱ្យតែទៅកន្លែងណាមួយគេដេញទៅកន្លែង
នោះ កន្លែងនោះមានបាយហូប គេទទួលបាយ ចេះតែដេញយើង យើងចេះតែទូលទាំងយប់
ទាំងថ្ងៃ ចេះតែដើរទៅហើយ ចេះដើរហើយទៅ ស្បែកជើងអត់ផង ដើររហូតខ្លះទៅកើតកូន
កណ្តាលផ្លូវ ខ្លះទៅងាប់កណ្តាលផ្លូវ ហ្អែងមើលវាអញ្ចឹងហា។

កៈហើយទុកខ្មោចចោលកប់ចឹងទៅ?

ខៈ ហ្នឹងហើយ ខ្មោចហ្នឹងធ្វើម៉េចបើថានេះមានកន្លែងណាកប់ អាហ្នឹងជំនាន់ហ្នឹងគ្រាន់បើជាង
នេះ យើងអាចសុំមូលដ្ឋានគេនៅហ្នឹងនៅកោះធំហ្នឹងម្ចាស់គេអ្នកនៅហ្នឹងស្រាប់ហា។

កៈ ចាស!

ខៈ សុំទៅគេជីករកដីអីកប់ខ្មោចកប់អីងាប់ទៅ ហើយអ្នកឆ្លងទន្លេ
ឆ្លងទន្លេតាមផ្លូវហ្នឹងទៅអីទៅ រស់នៅហ្នឹងការងារគេឱ្យយើងធ្វើ
អឺ...ព្រលឹមឡើងចេញទៅម៉ោងប្រហែលជាម៉ោង៨

៩យើងចេញទៅធ្វើរហូតទាល់តែល្ងាចបានយើងមកផ្ទះវិញវេចបាយដាក់ស្មុកហ្នឹង
អាបាយពោតហ្នឹង ពោតសុទ្ធតែអត់មានលាយបាយទេ
ពេលណាបានអង្ករម្តងៗលាយឆ្ងាញ់ណាស់។

កៈ អូយ...ប៉ុណ្ណឹងក៏ឆ្ងាញ់មីងហ៎?

ខៈ ហ្នឹងហើយ ឆ្ងាញ់ណាស់ហើយបាយលាយពោត ហើយក្រពះហើយបានក្រពះយើងវាធ្វើ
ទុកខ្លាំងហ្អែងដឹងពោតក្រហមដាំរំងាស់ទំពាំ...។

កៈ ទំពាំតែរីកមីងអើយ។

ខៈ ហ្នឹងហើយ។

កៈ ឡើងរឹងនៅហ្នឹង។

ខៈ ចាស!

កៈ អាពោតហ្នឹងពោតទុំដែរតើមីងណោះ?

ខៈ ពោតទុំហា...ចាស។

កៈ ហើយមិនបានមកពីណាលោកអើយ។

ខៈ ដាំហា...គេដាំនៅនឹងក្រោយហ្នឹងយើងហ្នឹងទៅនាំគ្នាទៅដាំទៅ
ដាំពោតដាំអីដល់ពេលទុំទៅកាច់វាយកមកទៅដឹករទេះហាលទៅ
ឱ្យវាស្ងួតទៅយើងនាំគ្នាបកប្រឡេះៗទៅយកចែកគ្នាតាមក្រុមអញ្ចឹងទៅណាស់ហ្ន៎...គ្រួសារ
នេះមានប៉ុន្មាន៥នាក់ ប៉ុន្មានគីឡូអញ្ចឹងទៅគ្រួសារនេះប៉ុន្មានគីឡូអញ្ចឹងទៅចែកទៅ។

កៈ អាហ្នឹងពេលដំបូង ពេលនៅស្រួលហ្នឹងហ៎?

ខៈ ហ្នឹងពេលទើបទៅដល់ហា។

កៈ ហ្ន៎...!

ខៈ យើងនៅនឹងប៉ុន្មានខែនៅកោះធំ គេចាប់ផ្តើមនៅប៉ុន្មានខែកាលហ្នឹង
គេចាប់ផ្តើមជម្លៀសយើងចេញទៅ ដឹកតាមកប៉ាល់អ្នកខ្លះដឹកទៅតាមឡានទៅដល់ពោធិ៍សាត់
ពោធិ៍សាត់ងាប់ច្រើនណាស់ដោយសារអត់បាយ សម្លាប់ចោលផង
អត់បាយផងហើយអឺ...ខ្ញុំជិះកប៉ាល់អើយអានេះ។

កៈ តាមទន្លេយើងនេះហ្នឹងអី?

ខៈ ជិះកាត់ទន្លេសាប ឡើងកប៉ាល់សំប៉ាន
ហើយកប៉ាល់ហ្នឹងណែនទាំងអស់ហ្នឹងមនុស្សអត់មានកន្លែងដេកទេមានតែអង្គុយអញ្ចឹងនេះ
អង្គុយសុទ្ធអញ្ចេក មានតែកន្លែងអង្គុយអញ្ចឹង
ហើយហ្អែងដឹងប៉ុន្មានយប់ប៉ុន្មានថ្ងៃទម្រាំទៅដល់កំពុងធំ។

កៈ ចាស!

ខៈ កាត់ទន្លេសាប ហ្នុ៎...ខ្ញុំកាលហ្នឹងបើនេះនឹកឃើញ កាលនឹកឃើញក្រោយដូចនេះហា៎...
ហ្អែងមើលប៉ាខ្ញុំគាត់នេះហា៎...ឈឺហើយក្រុមគ្រួសារខ្ញុំអញ្ចឹងដែរហើយជិះទៅហ្នឹងហា...អើយ
ឃើញអ្នកឈឺដេកឈឺអញ្ចឹងទៅ ដល់ពេលងាប់ ងាប់ភ្លាមអញ្ចឹងទៅឱ្យរុំកន្ទេលហ្នឹងទម្លាក់។

កៈ ទម្លាក់ទឹកហ្មង?

ខៈ ទម្លាក់ទឹកហ្នឹងហើយ ច្បាស់ហា...អាហ្នឹងខ្ញុំឃើញច្បាស់នឹងភ្នែក
រុំកន្ទេលងាប់ដាច់ខ្យល់ហើយរុំកន្ទេលទម្លាក់ទឹកអញ្ចឹងទៅពួកទាហានអីហ្នឹងស្រែកទៅទម្លាក់
ចោលហើយអាខ្លះគ្នា ចុះទៅក្រោយកន្ទុយកាណូតហ្នឹងជូសទឹកអីអញ្ចឹងទៅ
ជូសទឹកទន្លេអីអញ្ចឹងហា...ហើវាជ្រុល ហើយចុះ បោះចេះទៅដូចវាហាក់
វាជ្រុលអាកប៉ាល់កំពុងតែលឿនបើកហាក់ធ្លាក់ព្រួងទៅ ស្រែកហៅឱ្យឈប់អត់ឈប់ទេ
ងាប់ទន្លេសាបកណ្តាលទន្លេសាបល្វឹងល្វើយអញ្ចឹងទៅ
ហ្នឹងហើយដើរទៅបត់ជើងតាមបង្កន់កប៉ាល់មិននៅក្រោយ វេទនាណាស់អើយដើរអត់រួចទេ
រកកន្លែងដើរមិនកើតទេ។

កៈ អើយ!

ខៈ វាចង្អៀតមួយយប់ហ្នឹងអង្គុយអញ្ចឹងវាអត់ងងុយយើង។

កៈ អាណោចអាធមងាប់ហើយមីងពេលហ្នឹង?

ខៈ អនិច្ចាខ្លួនណាស់ពេលហ្នឹង ដល់ពេលនោះព្យុះ ព្យុះទៅខ្យល់ភ្លៀងព្យុះ ហូទន្លេសាប
កណ្តាលទន្លេសាបហា។

កៈ ធំហា៎...ណាស់មីងហា?

ខ៖ ហ្នឹងហើយ ស្រាប់តែជួបព្យុះខ្យល់អឺ...មកហើយកប៉ាល់ហ្នឹងហើយស្រាប់វាស្រែកថានៅឱ្យស្ងៀម
ហើយមនុស្សវាជ្រួលច្របល់ភ័យហាំ...វាស្រែកថានៅឱ្យស្ងៀមអាណានៅអត់ស្ងៀមវាយកអាណាដេញដំបងដើរវ៉ៃក្បាលពុៗៗអឺ...ខ្ញុំថាងាប់ហើយ ហើយនៅឱ្យស្ងៀម
ដល់ហើយវាអែបកប៉ាល់មកឡើងមកទប់កប៉ាល់បើកមកឱ្យកៀកគ្នាជាប់គ្នាអញ្ចឹងវាទប់កុំឱ្យរលកខ្លាំងហា។

ក៖ ចាស!

ខ៖ ហើយដល់ពេលរាងស្ងប់តិចបានវាចូលទៅកំពង់ឆ្នាំងទៅអែបនឹងកំពង់ឆ្នាំងកណ្តាលអាធាត្រហ្នឹងហើយវាប្រាប់ថាឱ្យយើងហ្នឹងដាំបាយដាំអីស៊ីទៅវាកណ្តាលអាធាត្រហើយទៅរកអីខ្ញុំសួរឯង។

ក៖ ហើយអត់មានអង្ករអត់មានអីណាហី?

ខ៖ អង្ករយើងមានដាក់វាឱ្យយើងទៅហា។

ក៖ ហ្ហ៎...!

ខ៖ អាអង្ករពោតហ្នឹងហា។

ក៖ ចាស!

ខ៖ វាថា ទៅដាំបាយដាំអីទៅមានអី ធ្វើអីឱ្យហើយទៅ ហើយហ្នឹងបើសិនជាខ្ញុំវិញ
ខ្ញុំអត់បាយងាប់បាត់ហើយទៅរកឯណាទេ ថាម្តាយធំខ្ញុំហ្នឹងហា...កម្សត់កម្រណាស់យាយហ្នឹងទៅ កន្ទៀតពោត អាពោតហើយឆ្នាំងមួយហ្នឹងហើយទៅ
ដើរចុះទៅឆ្លងស្ពានចុះកប៉ាល់ច្រើននោះដើរទម្រាំទៅដល់ខាង
ចេះសំណាងព្រះជួយដែរដូចនៅសល់គេទើបដាំហើយនៅរងើកនៅកន្ទុយអុសហា...គាត់ដាក់ដាំទៅបានហូបទៅដាក់ត្រីដាក់ស្អីដូចបានអីហូបទេ ដូចស្អីហ្ហ៎...មាន់អាលីងសាច់មាន់។

ក៖ បានមាន់ទៀត?

ខ៖ ចាសដូរគេយកពោតដូរគេ ដូរមាន់រស់ពោតលីងសាច់មាន់ហ្នឹងទុកហើយបានឆ្អិនមក
ហើយអ្នកខ្លះរកអត់បានហា...ខ្ញុំឃើញហើយពូមួយនោះនៅជិតខ្ញុំដែរនៅឡូតដូនេះស្រាប់តែប្តីប្រពន្ធគាត់ គាត់ទៅគាត់ទៅរកអីអត់បានគាត់ទៅទាញអាគេធ្វើក្បាំងគេដាំដើមដូងហើយគេ

ដាក់ពន្ធ័របងដើមដូងអញ្ចឹងហា...គាត់ទៅទាញអារបងគេហ្នឹងយកមក យោធាគេឃើញចាប់ចងស្លាបសេកបណ្ដើរទៅបាត់ ទៅបាត់ហ្នឹងទៅវៃចោលហើយ ហើយប្រពន្ធកូននៅលើកប៉ាល់នេះអត់ដឹងវេទនាណាស់ហា។

ក៖ ហើយគ្រាន់តែទាញសោះហ្នឹង?

ខ៖ ទាញយកមកដុតដាំបាយហា។

ក៖ ហ៊ឺ...ក្រែងឱ្យគេដាំបាយហេ?

ខ៖
ដាំបាយហ្នឹងហើយយើងមិនដឹងទៅរកអុសនៅឯណាយើងមិនទៅយករបងគេអញ្ចឹងអត់បានទេណាស់។

ក៖ ចំហ៊ឺ...ប៉ះពាល់បន្តិចមិនបាន។

ខ៖ ហ៊ឺ...ខ្លាចវាចោរម្រាយហើយ។

ក៖ ហើយដោយសារវាកាន់កាំភ្លើងនៅជាប់នឹងដៃរហូតមែនអ្នកមីង?

ខ៖ ចាសស្ពាយកាំភ្លើងរហូតពួកហ្នឹង អត់មានថាអត់កាំភ្លើងទេហ្ន៎...ជីវិតប៉ុល ពតហ្នឹងវេទនាណាស់ហ្ន៎...ប៉ុន្តែខ្ញុំ ខ្ញុំចេះតែខំប្រឹងធ្វើការ អឺ...យើងនៅវ័យប៉ុណ្ណឹងដែរយើងចេះតែខំធ្វើការល្អឱ្យគេទៅយើងកុំខ្ជិលហា។

ក៖ ចាសអាណាខ្ជិលក៏មិនបានដែរ
ហើយខុសសីលធម៌តែរាងអីស្រីញីអីប្រុសឈ្មោលអីរាងផ្អៀងផ្អងអីដាក់គ្នាហ្នឹងម៉ោកហើយហៅឱ្យទៅកសាងម្ដង មួយដងពីរដងហ្នឹងអីវ៉ៃចោល។

ក៖ អើយ!

ខ៖ ប្រាប់ហ្អែង...។

ក៖ ចាសចុះពីពេលលើទូកពេលទៅដល់ហ្នឹងអ្នកមីងទៅខេត្តណាវិញ?

ខ៖ ទៅកំពង់ធំ កំពង់ធំហ្នឹងឡើងទៅអញ្ចឹងគេឱ្យនៅម្ដុំអញ្ចឹងទៅអឺ...នេះឡាន ហា...មិនមែនឡានទេ ឡានគេដឹកហ្នឹងហើយ គេហៅឡើងដឹក ដឹកឡានទៅដល់រវៀងខ្ញុំ ខ្ញុំគេទម្លាក់នៅ ត្រឹមរវៀង រវៀងខេត្តព្រះវិហារ។

កៈ អើយឆ្ងាយ?

ខៈ ចាស!

កៈ មីងមិនព្រមរត់ទៅថៃហ្មងទៅអត់?

ខៈ ដឹងស្គាល់អីផង ហើយទម្លាក់នៅព្រះវិហាររួចគេនាំយើងដើរហ្មង អត់មានជិះឡានទេដើរ ចូលទៅតាមភូមិដូចថាប៉ុន្មានគ្រួសារនៅភូមិនេះ ភូមិនេះៗនៅក្នុងព្រៃម្តុំៗហ្នឹងចុះពួកគួយ ពួកក្នុងហ្នុំ...នៅជាមួយពួកហ្នឹងហើយដើរអាអើយ...មិនដឹងដីប៉ុន្មានគីឡូទេ និយាយពីចុកចាប់ជើងអស់ហើយរឹងអស់ហើយក្តៅ។

កៈ ចាស!

ខៈ ខ្ញុំអាណិតប៉ាខ្ញុំគាត់ចាស់ដើរហើយប្អូនខ្ញុំតូចនេះ អាពៅហើយគ្នាទើបបីឆ្នាំទេពេលហ្នឹង។

កៈ ចាសហើយប៉ាអ្នកមីងគាត់ឈឺស្លាប់នៅឯណាវិញ?

ខៈ ស្លាប់ ស្លាប់នៅព្រះវិហារហ្នឹងទៅដល់បានប៉ុន្មានគាត់ចាប់ឈឺ ដូចវាមិនមែនគ្រុនចាញ់ទេ ដូចក្តៅស្លាប់ គាត់ទៅអត់បានយូរទេស្លាប់។

កៈ គាត់ស្លាប់ឆ្នាំ១៩៧០ប៉ុន្មានមីង?

ខៈ ប្រហែលជាមើលកាលគាត់ស្លាប់ប្រហែលជា៧០(១៩៧០)ចុង៧០(១៩៧០)ហ្នឹង។

កៈ ហេ...៧០(១៩៧០)លន់ នល់ហ្នឹង។

ខៈ ហា...៧០ គាត់ទៅដល់បានប៉ុន្មានខែទេបានស្លាប់។

កៈ អញ្ចឹងនៅក្នុង៧៥(១៩៧៥)?

ខៈ ៧៥(១៩៧៥)ចាសនៅក្នុង៧៥ហ្នឹង(១៩៧៥)គាត់ស្លាប់ ហ្នឹងហើយ។

កៈ អាណិតណាស់អញ្ចឹងមីងណោះ?

ខៈ ចាស!

កៈ ហើយដល់ពេលអញ្ចឹងដល់ជីវិតអ្នកមីងនៅក្នុងពេលហ្នឹងដូចជាហូបចុកម៉េចដែរ ដល់ពេលបន្ទាប់ហ្នឹងមានអី...ពួកហ្នឹងបង្អត់អីឱ្យពិបាកអីអត់?

ខ៖ ចូលយើងចូលទៅសហាគមន៍គេដូចថាគេឱ្យភូមិហ្នឹងយើងទៅនៅហ្នឹងប៉ុន្មាននាក់អ្នកថ្មីហ្នឹងប៉ុន្មានគ្រួសារអញ្ជឹងទៅ ហើយគេមានផ្ទះបាយរួមគេថាដល់ម៉ោងបាយហ្នឹងគេវ៉ៃជួងពើងៗយើងហ្នឹងកាន់ចានទៅ
ទៅផ្ទះបាយរួមហ្នឹងទៅហើយបាយគេវាល់ហើយស្រាប់បបរពិខាប់ៗដាក់មួយកូនចានចង្កឹះហ្នឹង យើងយកអាណាទៅដាក់ហូបទៅជាមួយអំបិល ពេលណាមានអំបិលហូបអំបិល ពេលណាត្រួយដំឡូងគេស្លរត្រួយដំឡូងទៅកកដូចបាយជ្រូកអញ្ជឹងសម្លរគេហ្នឹង។

ក៖ ចាស!

ខ៖ យើងចេះតែដូសហូបនឹងគេទៅព្រោះអីឱ្យតែឆ្អែត។

ក៖ កុំឱ្យតែកូរពោះទៅ។

ខ៖ ពេលមានសាច់ទៅព្រានព្រៃគេទៅបាញ់បានសត្វអញ្ជឹងមកទៅគេចែកទៅតាមតិចៗដាក់ក្នុងសម្លរហ្នឹងទៅ។

ក៖ ហើយពេលអាពតនៅហ្នឹងច្រើនអត់មីង?

ខ៖ មិនមែនអាពតទេ យោធា។

ក៖ យោធាហ្នឹងគេគ្រប់គ្រងមែនទេ?

ខ៖ ក្រុមយោធាពួកខ្ញុំ
បើពួកខ្ញុំត្រូវអតីតជាអ្នករដ្ឋាការណ៍អញ្ជឹងហា...ដូចថាពូជអំបូរយើងខ្សែស្រឡាយយើង យើងជាអ្នកធ្វើការអញ្ជឹងគឺវាប្រមូលយើងយកមកដាក់មួយដុំ គេហៅអ្នកគេ យកដាក់គុកសម្រាប់អ្នកដូចថាយើងឪពុកម្ដាយយើងបងប្អូនយើងធ្វើទាហាន ធ្វើអីធ្វើមន្ត្រីរាជការអញ្ជឹងហា។

ក៖ ចាស!

ខ៖ វាយកយើងដាក់មួយដុំហ្នឹងហើយមានអតីតភាពអញ្ជឹងវាដាក់យើងមួយដុំ ទៅវាលត់ដំយើង ប៉ុន្តែខ្ញុំទៅដល់គេលន់ដំឆ្អែតហើយពួកហ្នឹងហ្ន៎...អង្ករមួយកំប៉ុងបបរមួយខ្ទះ ហ្បែងគិតមើលបើមានក្ដួចដាក់ក្ដួចមានត្រួយដំឡូងដាក់ត្រួយដំឡូងកូរទៅ ដួសគ្នាមួយវែកៗហុតទៅហើយខ្ញុំទៅដល់ហ្នឹងវារាងសម្បូរបែបតិចហើយ ហ្នឹងគេធ្វើបានស្រូវហើយណាស់បានហូបបានបាយ ពេលណាអត់ខែស្រូវអញ្ជឹងបបរពិ

វាល់កូនចានចង្កឹះហ្នឹងទៅញ៉ាំទៅមានសម្លរហុតសម្លរបន្លែបង់អំបិលហ្នឹងទៅណាស់ ថាដំឡូងដាក់ដំឡូងត្រួយដំឡូងអញ្ចឹងទៅដាក់អំបិលទៅយើងដូសមកសម្លរហើយហ្នឹង ដើមចេក ហើយដើមចេកក្ដួចៗទៅលាយបាយដើមចេក គល់ ចេកលាយបាយ។

កៈ មានគ្រឿងអីអត់មីង?

ខៈ អត់មានគ្រឿងទេ យូរៗបានមានប៊ីចេងម្ដង រាងមានជាតិទៅ។

កៈ មានអញ្ចឹងទៅ។

ខៈ មានបុកស្លឹកគ្រៃ។

កៈ ហើយដូចជាចុះម្ដាយអ្នកមីង ឪពុកអ្នកមីងគាត់ម៉េចដែរជីវិតរបស់ពួកគាត់អញ្ចឹងហាំ?

ខៈ រស់នៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

កៈ ចាស!

ខៈ ប៉ាខ្ញុំស្លាប់ដោយសារមិនអត់បាយទេថា
ដូចថាគាត់ពិសារបាយទៅអញ្ចឹងហា...បើម្ដាយធំខ្ញុំនេះ ម្ដាយដើមខ្ញុំនេះទៅរោងបាយអញ្ចឹង បានគេហៅថាបាយចាក់បំពុង គាត់ហូបតែមួយកំនណាត់ទេ គាត់លាក់ លាក់មួយកំណាត់ហ្នឹង លាក់ក្នុងចានហ្នឹងអឺ...រុំក្រមាចុះមក មកអញ្ចឹងមកដល់ផ្ទះអញ្ចឹងគាត់ដាក់ទឹក ហើយគាត់ពៀចដាក់ ទឹកអញ្ចឹងកូរ កូរឱ្យរលួយអញ្ចឹង ព្រលឹមឡើងដូសចែកកូនហុតទៀត។

កៈ ហ៊ឺ!

ខៈ ហ្នឹងហើយកម្សត់ហា...គាត់ហា។

កៈ ចាសហើយពេលហ្នឹងបន្លែ ផ្លែឈើឥវ៉ាន់មានច្រើនអត់អ្នកមីង?

ខៈ ដីយើងដាំគេឱ្យដាំដំឡូងដាំអីអញ្ចឹង ប៉ុន្តែយើងបេះអត់បានទេ។

កៈ ហើយយកទៅណា?

ខៈ គេបេះដាក់រួម បេះដាក់ផ្ទះបាយ បន្លែសណ្ដែកដំឡូងអីអញ្ចឹងហា។

កៈ តែមិនដែលបានហូបទេអី?

ខៈ បានគេចុះស្លរនោះយើងមិនហូប។

ក៖ ចាស!

ខ៖ គេស្លូររួមហើយយើងមិនហូបទៅ។

ក៖ ចាសយ៉ាប់ដែរហ្នឹងអញ្ចឹង។

ខ៖ ហើយ...ជីវិតបើនិយាយវាអត់ ខ្ញុំឈឺ ឈឺទៅដល់ចាញ់ ខ្ញុំគ្រុនចាញ់ហា...ក្តៅ។

ក៖ ចាស!

ខ៖
ធំលែងដឹងខ្លួនមើលឡើងលែងដឹងអីទាំងអស់ហើយខ្លួនប្រាណខ្ញុំហ្នឹងសឹងតែនឹងស្រាតទាំងអស់ហ្នឹងវាក្តៅម្នាក់ៗហា...ហ្នឹងហើយខ្ញុំស្លៀកខោមិនដឹងប៉ុន្មានជាន់ទេ
មិនដឹងម៉េចទេម៉ែខ្ញុំគាត់ឱ្យស្លៀក
រួចទៅវាស្រោលអានលអានលទាំងអស់ក្តៅពេកហា...ដេកពេទ្យគេយកទៅឱ្យដេកពេទ្យ
គ្រែមួយវាលហ្នឹងទៅ ផ្ទះមួយគេធ្វើពេទ្យគេ ខ្ញុំអាហ្នឹងខ្ញុំនិយាយប្រឹសៗ ដឹងខ្លួនបន្តិចហើយ
មើលទៅសុទ្ធតែឃើញស្រាតឡើងអានល អានលស្រែកទឹកហើយ...ទារតែទឹក  ផឹក។

ក៖ ឈឺអីគេមីងបានដល់ថ្នាក់ហ្នឹង?

ខ៖ គ្រុនចាញ់។

ក៖ ហូយ...ចាញ់ហ្នឹងពិបាកហ្មងមីងណេះ?

ខ៖ គ្រុនចាញ់ហើយអត់មានថ្នាំ ផឹកតែថ្នាំអាចមន៍ទន្សាយហ្នឹង
ហើយខ្ញុំមើលឃើញគេអញ្ចឹងខ្ញុំស្លៀកខោច្រើនជាន់ ពួកហ្នឹងស្រាតអានលៗ
ពួកហ្នឹងសែងមកតែមួយយប់ទេ ឃើញស្រែក
ហោៗភ្ញាក់ឡើងបាត់មាត់ព្រលឹមឡើងងាប់បាត់។

ក៖ ភាគច្រើននៅព្រះវិហារចាញ់ណោះ?

ខ៖ ចាញ់ខាងពោធិ៍សាត់រ៉ៃចោលអត់បាយ នៅព្រះវិហារចាញ់ ហើយខ្ញុំអាពេទ្យហ្នឹងមកច្រើន
ណាស់មកងាប់ៗទាំងអស់រស់តែខ្ញុំ២នាក់គត់។

ក៖ អើយ!

ខ៖ ងាប់អស់រលីង នៅតែខ្ញុំ២នាក់បងមួយនោះ ដល់ពេលខ្ញុំនិយាយគេងាប់អញ្ចឹងខ្លាចខ្មោច ចុះខ្មោចងាប់ជុំវិញខ្លួនហ្នឹង។

ក៖ ខ្លាចដែរ?

ខ៖
អើយ...ខ្លាចផ្ទះយើងនេះស្ងាត់តែឯងស្រែកប្រាប់ថាបងពេទ្យអើយបងពេទ្យជួយមើលកំដរខ្ញុំផងខ្ញុំខ្លាច។

ក៖ ចាស!

ខ៖ ពេទ្យនារីគេហ្នំ...មិនអីទេមិត្ត។

ក៖ ចាស!

ខ៖ ចឺសមមិត្តខ្ញុំនៅកំដរមិត្តគេនៅដុតភ្លើងហ្នឹងហើយរងាណាស់។

ក៖ ហើយអត់មានអីដណ្ដប់ទេមឹងណេះ?

ខ៖ ដណ្ដប់តែអាក្រណាត់គេចែកហ្នឹង ហើយគេដាក់ភ្លើង គេអាំងអញ្ចឹងទៅគេឃើញព្រលប់គេអង្គុយយប់ឡើងយើងដេកលក់វាទៅអស់វាទៅដេកអស់ ឯងភ្ញាក់អត់មានឃើញអ្នកណារលីង ហើយដល់ពេលហ្នឹងបងហើយខ្ញុំ២នាក់ដេកទល់ខ្នងគ្នា យកខ្នងទល់គ្នា គ្រប់ខ្លាច ខ្លាចខ្មោចលងតែដូចអត់ដែលឃើញអីដែរ។

ក៖ លែងមានអាណាលងអាណាគេកើតហើយ ដល់ច្រើនពេក។

ខ៖ ខ្មោចជុំវិញខ្លួន ខ្លាចអើយខ្លាច។

ក៖ អញ្ចឹងអ្នកមីងតើដូចជាអ្វីដែលចាំបំផុតនៅក្នុងជីវិតមីងគឺអីគេជាងគេបំផុតទៅ?

ខ៖ ជីវិតដែលខ្ញុំភ័យបំផុតគឺដែលខ្លាចជាងគេ ទី១គឺជិះកប៉ាល់ដែលនៅកណ្ដាលទន្លេ កណ្ដាលទន្លេសាបហ្នឹងមួយ
ខ្ញុំចងចាំភ័យអារម្មណ៍ហា៎...ភ័យក្រោយអាពេលហ្នឹងយើងអត់ដឹងថាភ័យទេ ពេលហ្នឹងគិតមកឥឡូវយើងគិតទៅភ័យក្រោយហ្នឹង។ហើយមួយទៀតនៅក្នុងជំនាន់ហ្នឹងខ្ញុំពេលដែលគេចាប់ខ្ញុំនិងក្រុមគ្រួសារខ្ញុំបញ្ជូនចេញពីភូមិ
ភូមិចាស់មកភូមិថ្មីហា...ពីភូមិអតីតភាពអ្នករដ្ឋាការ គេឱ្យយើងចេញពីភូមិ
ចូលមកកន្លែងក្រុមអ្នកថ្មីដូចគេហា...មើលទៅដូចគុកអញ្ចឹងហា។

កៈ ចាស!

ខៈ អាហ្នឹងកន្លែងហ្នឹងជិះមកភូមិជិតគ្នាសោះតែវាធ្វើដំណើរឱ្យវាចេញយប់
ហើយមកវាចូលឱ្យយើងដេកផ្ទះខ្ទមមួយស្ងាត់ហើយវាឆែក ឆែកយើងទាំងអស់
កាបូបយើងអីយើងអីៗ សាក់កាដូយើងអីយើងឆែកមានអីវាយករបស់យើង
ពេលហ្នឹងបើសិនជាវាសម្លាប់យើង៣គ្រួសារហ្នឹងងាប់អស់ទៅហើយវាយកទៅវៃចោលអស់
ទៅហើយតែដូចប្រេងសំណាងវាអត់ងាប់
ខ្ញុំនៅមានអារម្មណ៍ភ័យក្រោយនៅកន្លែងហ្នឹងទៀត។

កៈ អាពតនៅកន្លែងណាក៏មានដែរណោះមីង?

ខៈ ហ៊ឺ...ពេញទាំងអស់មានអ្នកណាគេចផុតទេ ហើយយើងដូចកាលហ្នឹងមនុស្សយើងដូច
បាក់ខ្លាចគេណាស់ មនុស្សទាំងហ្វូង ។

កៈ ពេញប្រទេសខ្លាចវាទាំងអស់។

ខៈ ដូចត្រូវទំនាយម៉េចហោ។

កៈ
គិតទៅវាមិនដែលមានអញ្ចឹងទេមីងណោះ?អូយ...ពិបាកណាស់អញ្ចឹង។អញ្ចឹងអ្នកមីងដូចពេ
លបន្ទាប់មកអ្នកមីងបានរៀបការជាមួយលោកពូអញ្ចឹងទៅ?

ខៈ ចាសរៀបការហើយទម្ងន់កូនទី១របស់ខ្ញុំបងគេហ្នឹង វាបញ្ជូនយើងចេញពីកន្លែងហ្នឹង
ទៀត។

កៈ ចាស!

ខៈ ចាសទម្ងន់៥ខែ បញ្ជូនទាំងយប់ហ្នឹង
អ្នកណាមួយក៏គេថាយកទៅវៃចោលដែរប្រហែលយកទៅចាក់ចោលនៅជ្រោះណាហើយ
អ្នកណាអ្នកស្រុកនៅតាមមូលដ្ឋានហា...គេជញ្ជូន
ឡានគឹកគាក់ៗទាំងយប់ហើយឡើងទៅវាយើងទៅដាក់។

កៈ ២នាក់ប្ដីប្រពន្ធមីងអត់?

ខ៖ គ្រួសារខ្ញុំម្ដាយឪពុកខ្ញុំ ពុកខ្ញុំស្លាប់ហើយ
បងប្អូនហើយម្ដាយខ្ញុំ២នាក់ហ្នឹងបញ្ជូនទៅកន្លែងភូមិមួយទៀត ហៅថាដំណាក់ត្រាច
ចេញពីអូររំដួលពីដំណាក់ត្រាចទៅអូររំដួល កន្លែងគុកមួយទៀត។

ក៖ ចាសអញ្ចឹងបន្តបន្ទាប់ទៀតទៅ?

ខ៖ ចាសបន្តបន្ទាប់ទៅបានខ្ញុំមានកូនមកបានយើងបែកនៅ កន្លែងហ្នឹងអូររំដួលហ្នឹង ជំនាន់យួនឡើងទៅវៃបែក។

ក៖ ចាសហើយដល់ពេលយួនចូលអញ្ចឹងទៅបានអ្នកមីងវិលត្រលប់មកភូមិកំណើតវិញអញ្ចឹងទៅ?

ខ៖ ចាសយើងចូលមកអញ្ចឹងទៅយើងមានលទ្ធភាពយើងមានស្រូវអីយើងដូរយកមាសយកអីយើងជួលយកឡានជិះមកគេដឹកស្បៀងពីព្រះវិហារមកភ្នំពេញ
ពីភ្នំពេញព្រះវិហារហ្នឹងហើយពួកខ្ញុំជួលគេយកស្រូវលក់ស្រូវ ចុះស្រូវយើងធ្វើបានអញ្ចឹងលក់ស្រូវដូរជាមាសទៅ ជួលឡានជិះមកស្រុក ។

ក៖ ចាស!

ខ៖ ហើយផ្ទះមានអីអាលីងអត់មានអីសោះមកនៅទៅបានទៅជ្រកផ្ទះ
ខាងមុខម្ដាយមីងគាត់មកមុនគាត់ឱ្យនៅសិនទេ បានយើងនាំគ្នាទៅច្រូតកក់ទៅក្រោយ
នៅឯបឹងក្រោយហ្នូ...មក ទិញឬស្សីបានអាមួយមិត្តភក្តិបងប្រុសខ្ញុំហ្នឹង
ឃើញខ្ញុំមកវិញគេនៅអូស្រ្គាលីហ្នុំ...គេចេញរួចហា...គេដើរមកឃើញខ្ញុំអញ្ចឹងគេឱ្យខ្ញុំមួយជីហេ...គេមានគេហុចឱ្យខ្ញុំ១ជីមកយើងដូរមកទិញដើមឬស្សីមកធ្វើសសរផ្ទះដល់ហើយត្បាញកក់ច្រូតហើយយកមកហាលត្បាញអីអញ្ចឹងទៅយើងសង់ឱ្យគេជួយលើកផ្ទះហ្នឹងឱ្យសង់ផ្ទះស្បូវមួយនៅទៅ។

ក៖ ទ្រាំៗសិនទៅមីងហេ?

ខ៖ ចាស!

ក៖ ពេលហ្នឹងទាំងអស់សុទ្ធតែស្មើគ្នាទាំងអស់មីងហ៎?

ខ៖ ចាស!

ក៖ អញ្ចឹងអ្នកមីងបន្ទាប់ពីអ្នកមីងចាប់ដៃគ្នាជាមួយនឹងលោកពូមកតាំងពីប៉ុល ពតរៀបឱ្យហ្នឹងមកតើមីងមានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូន៣នាក់។

ក៖ ចាស!

ខ៖ ស្រី២ប្រុស១។

ក៖ ចាសអញ្ចឹងអ្នកមីងអាចរៀបរាប់ឈ្មោះគាត់តាំងពីបងដល់ពៅគេតើគាត់ឈ្មោះអីគេខ្លះ?

ខ៖ កូនច្បងខ្ញុំស្រី ចាសហើយកូនទី២ស្រីទៀត កូនទី៣ប្រុសមិញហ្នឹង។

ក៖ ចាសគាត់ឈ្មោះអីគេខ្លះមីង?

ខ៖ កូនទី១ឈ្មោះ ស៊ុយ ញឹប។

ក៖ ចាស!

ខ៖ ហើយកូនទី២ឈ្មោះ ស៊ុយ សុជាតា កូនទី៣ឈ្មោះ ស៊ុយ សុកាណែល។

ក៖ ចាសអ្នកមីងមានឱ្យកូនទៅរៀនអត់អ្នកមីង?

ខ៖ រៀនទាំងអស់។

ក៖ ចាសសុទ្ធតែទៅទទួលការសិក្សាទាំងអស់គ្នា?

ខ៖ ចាសទៅសិក្សាទាំងអស់។

ក៖ អ្នកមីងគិតថាការសិក្សាមានសារៈសំខាន់យ៉ាងម៉េចចំពោះពួកគាត់ដែរ បានអ្នកមីងបញ្ជូនគាត់សាលាអញ្ចឹងហាំ?

ខ៖ ចាសគឺថាខ្ញុំក៏ធ្លាប់ឪពុកខ្ញុំជំនាន់ៗបងប្អូនខ្ញុំអីក៏រៀនបានខ្ពស់ៗទាំងអស់គ្នា នាំគ្នាគិតថាការសិក្សាដូចថាទទួលនូវចំណេះដឹងសម្រាប់យើង ហើយយើងក៏ចេះធ្វើខ្លួនយើងឱ្យចេះជាមនុស្ស ល្អឱ្យស្គាល់ពីសង្គមយ៉ាងម៉េច ល្អអាក្រក់យ៉ាងម៉េចយើងយល់ គេថាមនុស្សអត់ចេះអក្សរល្ងង់វាអត់ដឹងអីទេ មនុស្សចេះអក្សរវាដឹងពីច្បាប់ទម្លាប់សព្វបែបយ៉ាងទាំងអស់ចាស ហើយម្លោះហើយបានខ្ញុំជម្រុញកូនឱ្យទៅទាំងអស់អត់មានឱ្យអ្នកណាឈប់មួយទេ

គ្រាន់តែថាពេលប្រលងកូនបងខ្ញុំហ្នឹងវាប្រលងឌីប្លូមទាំង២ឆ្នាំ
ធ្លាក់ទាំងពីរឆ្នាំហ្ន...ក៏ឱ្យឈប់ទៅ។

កៈ ចាស!

ខៈ ឈប់ទៅ ទៅធ្វើការរោងចក្រទៅ
ហើយកូនទី២បានជាប់បាក់ឌុបហើយតែទៅរៀនហា...ជាប់ឌីប្លូមហើយតែទៅរៀនតែយើងខ្វះ
សមត្ថភាព សំពត់មួយអាវមួយពត្អក់ ជិះទៅបឹងត្របែក អត់មានអីជិះ ជិះរ៉ឺម៉ក់ ជិះរ៉ឺម៉ក
ចុះត្រឹមក្បាលថ្នល់ដើរទៅទៀត
ដើរទៅទៀតហើយគ្នាមានការហត់នឿយម្ល៉ោះហើយខោអាវយើងវាមិនស្មើជាមួយពួកភ្នំពេញ
ទេ ហើយយើងពេលចេញមកយើងអត់មានលុយណាទិញអីញ៉ាំទេ
ព្រោះឪពុកម្តាយក្រម្ល៉ោះហើយគ្នាខ្មាស់គេឈប់ខ្លួនឯងហ្មង
ឈប់ខ្លួនឯងបានបន្តអាជីពធ្វើសក់ ផាត់មុខអីទៅវារៀននៅអង្គការ។

កៈ ហើយបើកធ្វើជាជាងអ៊ុតសក់អញ្ចឹងទៅ?

ខៈ ចាស!

កៈ
ចាសអញ្ចឹងអ្នកមីងដូចអ្នកមីងធ្វើម៉េចដើម្បីឱ្យក្រុមគ្រួសារអ្នកមីងមានសុភមង្គលដែរនៅពេលរ
ស់នៅជាមួយស្វាមីនិងកូនអញ្ចឹងហាំ?

ខៈ កូនចៅទាំងអស់ហ្នឹងគេបែក បែកគ្រាន់តែថាផ្ទះនៅជាមួយគ្នាតែបែកឆ្នាំង បែងចែកបន្ទប់
គ្នាតែបែកឆ្នាំង តែខ្ញុំនៅជាមួយកូនប្រុសពៅខ្ញុំនេះ។

កៈ ចាស!

ខៈ ជីវិតខ្ញុំរស់នៅជាមួយគេដូចថាខ្ញុំចាស់ហើយខ្ញុំអាយុច្រើនហើយ។ សព្វថ្ងៃប្តីខ្ញុំគាត់ប៉ះកង់
ប៉ះកង់រហូតតាំងពីដើមមក ធ្វើការផងប៉ះកង់ផងដល់ឥឡូវគាត់អ៊ីត្រែតទៅគាត់ប៉ះម៉ូតូអញ្ចឹង
ឥឡូវកន្លែងវាចង្អៀត។

កៈ នៅខាងមុខហ្នឹងមីងអី?

ខៈ ចាសគាត់ប៉ះម៉ូតូ ប៉ះអីអញ្ចឹងទៅ ជួនណាមានគេមករកទៅប៉ះអញ្ចឹងទៅ អត់ទៅហីទៅ។

កៈ ចាស!

ខ៖ ហើយគាត់ចេះជុសជុលកង្ហារអីទៅគ្រាន់តែតក់ៗទៅ។

ក៖ ចាស!

ខ៖ ហើយឥឡូវជីវភាពគ្រួសារខ្ញុំវាពឹងផ្អែកទាំងស្រុងទៅលើកូនប្រុសពៅខ្ញុំមិញហ្នឹង។

ក៖ គាត់ធ្វើការអីគេដែរអ្នកមីង?

ខ៖ ចាសគាត់កាន់ស្ថានីយ៍នៅឧដុង្គ។

ក៖ ចាស!

ខ៖ កន្លែងភ្លើង កន្លែងបញ្ជារភ្លើងហ្នឹង។

ក៖ ហ្ហ៎...ហ្នឹងហើយ។

ខ៖ ចាសខាងហ្នឹង។

ក៖ ចាសចុះអ្នកមីងដូចជា
ដូចជាឥឡូវអាយុចំណាស់នេះហើយតើអ្នកមីងថ្ងៃអនាគតទៅអ្នកមីងសង្ឃឹមចង់បាននៅក្នុងជីវិតជាងគេទៅ?

ខ៖ សង្ឃឹមចង់បានអីឥឡូវ?

ក៖ ដូចជាអ្នកមីងរំពឹងចង់បានអីគេជាងគេ
បំពេញក្តីស្រម៉ៃសម្រាប់នៅអឺ...នៅពេលដែលអ្នកមីងមានវ័យពេលជំនាន់
ចំណាស់ហ្នឹងអញ្ចឹងហា៎?

ខ៖ ខ្ញុំអារម្មណ៍ខ្ញុំគិតថាថ្ងៃអនាគតទៅខ្ញុំចង់ឱ្យកូនគេទាំងអស់គេមានដូចថាមានមុខរបបមានការងារល្អធ្វើ។

ក៖ ចាសហ្នឹងហើយ!

ខ៖ សម្រាប់ជួយក្រុមគ្រួសារ ចៅៗខ្ញុំគាត់បានរៀនសូត្រហើយ មានចំណេះដឹងខ្ពស់ហើយគេមានការងារល្អៗធ្វើសម្រាប់គេឱ្យគេយល់ពីសង្គមយ៉ាងម៉េចខ្លះកុំឱ្យធ្លាក់ក្នុងការល្បួងពីមនុស្សអាក្រក់ទាញទៅ ដូចសង្គមឥឡូវ លេងល្បែងគ្រឿងញៀនអីហា...ចាសចង់អញ្ចឹងហើយអារម្មណ៍ខ្ញុំរាល់ថ្ងៃខ្ញុំសុំឱ្យមានសុខភាពខ្ញុំខ្ញុំយល្អទេព្រោះអីអត់ធ្វើអីទេឈឺម្តងៗខ្ញុំភ័យណាស់ ពិបាកក្នុងខ្លួនណាស់។

កៈ ចាសអ្នកមីងសូម្បីតែខ្ញុំនៅក្មេងផងនៅភ័យដែរហ្នឹងហាពេលឈឺអីវ៉ាន់។ ចាសអញ្ចឹងអ្នកមីងមួយនេះគឺជាសំណួរមួយចុងក្រោយដូចជាអ្នកមីងមានដំបូន្មានអីខ្លះចង់ផ្ដែផ្ដាំទៅកាន់កូនចៅមីងជំនាន់ក្រោយដែលគាត់នឹងឮសម្ដីរបស់អ្នកមីងហា...សូមអ្នកមីងរៀបរាប់ឱ្យបានក្បោះក្បាយចង់ឱ្យគាត់ដើរលើផ្លូវអញ្ចឹងហា?

ខៈ ចាសដសម្រាប់ខ្ញុំ
ខ្ញុំសូមសំណូមពរឱ្យកូនចៅជំនាន់ក្រោយៗទៀតមិនថាកូនខ្ញុំឬក៏កូនគេទេ
មិនថាចៅខ្ញុំឬក៏ចៅគេទេ
គឺថាសូមឱ្យពួកគេមានការសិក្សាចេះដឹងឱ្យបានច្រើនហើយឱ្យមានកម្រិតខ្ពស់ឱ្យយល់ដឹងពីសង្គមអ្វីដែលល្អនឹងអាក្រក់ហើយកុំឱ្យគេធ្លាក់នៅក្នុងការល្បួងរបស់មនុស្សអាក្រក់នាំទៅធ្វើអំពើអ្វីដែលមិនល្អ។

កៈ ចាស!

ខៈ ចាសហើយសុំឱ្យគេមានក្ដីសុខ សុខទាំងផ្លូវកាយផ្លូវចិត្ត។

កៈ ចាស!

ខៈ ចាសហើយកុំចង់ឱ្យមានបានហួសហេតុពេក ធ្វើម៉េចឱ្យតាមសមត្ថភាពអញ្ចឹងហាចាស។

កៈ ចាស!

ខៈ
យើងខំប្រឹងតាមសមត្ថភាពយើងចង់មានពេកយើងទៅជាពុករលួយទៅលួចលុយគេទៅធ្វើចោរធ្វើអីវាអត់កើតទេ ម្លោះហើយយើងធ្វើម៉េចឱ្យតែយើងមានការងារល្អធ្វើ
មានប្រាក់ខែល្មមសមរម្យអាចរស់នៅបានចាស។

កៈ ចាសឱ្យគាត់ដើរលើផ្លូវយ៉ាងម៉េចទៅមីង?

ខៈ ចាសដើរលើផ្លូវល្អទៅណាស់ កុំឱ្យប្រព្រឹត្តអំពើអាក្រក់។

កៈ ចាស!

ខៈ ចាស!

កៈ ហ្នឹងហើយ។អ្នកមីងមានអីទៀតអាចចង់ចែកចាយអីទៀតក៏បាន។

ខ៖ អស់ហើយសួតបំពង់ក។

ក៖
ចាសអញ្ចឹមរ្យរាប់ថ្ងៃនេះខ្ញុំអរគុណអ្នកមីងច្រើនមែនទែនសម្រាប់អ្វីនឹងបទពិសោធន៍សម្រាប់ជីវិតរបស់អ្នកមីងតាំងពីក្មេងរហូតដល់អ្នកមីងអាយុប៉ុណ្ណេះហើយខ្ញុំដឹងថាកូនចៅអ្នកមីងនឹងបានស្តាប់ឮពីជីវប្រវត្តិរបស់អ្នកមីងថាតើបានមានអីគេខ្លះអញ្ចឹងហា...អ្នកមីង។

ខ៖ ចាស!

ក៖ ចាសអញ្ចឹងអរគុណច្រើនណាស់អ្នកមីង?

ខ៖ ចាសអរគុណ៕